ឆ្នាំគ្រួសារ ២០១៧-២០២០

# អ្នកនាំសារ
# The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែសីហា ឆ្នាំ២០១៨ លក់តម្លៃ ១០០០រៀល

លេខ ១១៣

## កម្ពុជាឥឡូវបានសុខហើយ មិនចង់ឃើញទិដ្ឋភាពអ្វីកើតឡើង កាលពីទសវត្សរ៍នៃឆ្នាំ ១៩៧០-១៩៨០ នោះទេ



CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh
ចាងហ្វាង : លោក លី សុវណ្ណា
សេចក្ដីប្រកាសលេខ៖ ០២០/១៨ ព.ម.រ.ល.អ/ ០១-មករា-២០១៨

# ព្រះសហគមន៍មណ្ឌលគិរី




ខេត្តមណ្ឌលគិរី ស្ថិតនៅតំបន់ខ្ពង់រាបភាគខាងកើតនៃប្រទេសកម្ពុជា ជាប់ព្រំដែនជាមួយខេត្ត ដាឡាត់ នៃប្រទេសវៀតណាម ជាខេត្តមួយពោរពេញដោយសក្តានុភាពផ្នែកដំណាំឧស្សាហកម្ម និងទេសចរណ៍។ មានផ្ទៃដីធំទូលាយ មានព្រៃ ភ្នំ ទឹកជ្រោះដ៏ស្រស់ស្អាតនិងមានអាកាសធាតុត្រជាក់ដ៏ជាទីមនោរម្យ។

ខេត្តមណ្ឌលគិរី មានប្រជាជនភាគច្រើនជាជនជាតិភាគតិច ពូណង ដែលមានប្រមាណជាបីម៉ឺននាក់។ បងប្អូនទាំងនោះពេលនេះបានធ្វើសមាហរណ្ណកម្ម រស់នៅតាមបែបទំនើប ដែលនាំឲ្យបាត់បង់បន្តិចម្តងៗ នូវវប្បធម៌របស់ខ្លួន។

មានបងប្អូនពូណងជាច្រើនបានទទួលជំនឿសាសនាផ្សេងៗក្រៅពីជំនឿជជាតិដើម ដែលជឿលើអារក្ស អ្នកតាតាមព្រៃភ្នំ។ មានបងប្អូនមួយចំនួនបានទទួលជំនឿកាតូលិក ដែលមាននៅ ប៊ូស្រា នៅដាក់ដាំ និងនៅកែវសីមា។

ព្រះសហគមន៍កាតូលិក នៅតំបន់មណ្ឌលគិរី មានលោកបូជាចារ្យ ហ្វ្រង់ស្វ័រ អេមេល្យដាល ជាអ្នកទទួលខុសត្រូវណែនាំជំនឿរបស់ពួកគេឲ្យប្រសើរឡើង។ លោកបូជាចារ្យ ហ្វ្រង់ស្វ័រ បានទទួលការចាត់តាំងពីលោកអភិបាល ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាមដើម្បីរួមដំណើរជាមួយបងប្អូននៅខេត្តមណ្ឌលគិរី។

លោកបូជាចារ្យបានរៀបរាប់អំពីស្ថានភាព និងមុខងាររបស់លោកនៅក្នុងបេសក-កម្មនេះថា លោកចូលរួមជាមួយបងប្អូនណែនាំគេ អំពីពិធីបុណ្យ អប់រំជំនឿ និងសកម្មភាពមេត្តាករុណា នៅក្នុងភូមិព្រមទាំងសួរសុខទុក្ខអ្នកជំងឺ។

លោកបន្តថា នៅទីនេះបងប្អូននិយាយភាសាមួយផ្សេងទៀតក្រៅពីភាសាខ្មែរគឺភាសាពូណង តម្រូវឲ្យលោកត្រូវរៀនភាសាពូណង និងវប្បធម៌របស់ពូណងផងដែរ។ ចំពោះភាសាពូណង លោកបូជាចារ្យថា មិនពិបាកទេដោយសារលោកចេះភាសាខ្មែរហើយ ចំពោះការចូលក្នុងវប្បធម៌ពូណងពិបាក ព្រោះគ្មានសៀវភៅនិងអ្វីៗទាំងអស់ ហេតុនេះត្រូវតែរស់នៅក្នុងចំណោមគេ និងត្រូវការពេលវេលា។ តាមការអះអាង របស់បូជាចារ្យជាសាសនទូតរបស់ព្រះគ្រីស្ត បានឲ្យដឹងបងប្អូនបានប្តូរជំនឿមកគ្រីស្តសាសនា ព្រោះតែសាសនាដើមរបស់គេ ត្រូវចំណាយលុយកាក់ច្រើនលើពិធីយញ្ញបូជា ក៏ជាពិធីតាមប្រពៃណីផ្សេងៗទៀត និងធ្វើឲ្យគេមានការភ័យខ្លាចជាប់ជានិច្ច គ្រប់ពេលវេលា។

តាមការបាន់ប្រមាណ នៅមណ្ឌលគិរី មានគ្រីស្តបរិស័ទកាតូលិកប្រមាណ២០០នាក់ និងបងប្អូនគ្រីស្តបរិស័ទក្រុមជុំនំប្រូតេស្តង់ប្រមាណ២០០០នាក់ នៅក្នុងចំណោមបងប្អូនពូណង ប្រមាណជា៣ម៉ឺននាក់។

លោកបូជាចារ្យរៀបរាប់អំពីរបៀបបងប្អូនដែលសុំចូលព្រះសហគមន៍ គឺគេទាក់ទងនឹងគណៈកម្មការព្រះសហគមន៍ សុំចូល ហើយលោកបូជាចារ្យ និងគណៈកម្មការទៅទទួលគេនៅផ្ទះដោយអធិដ្ឋាន ពួកបានលះបង់ជំនឿចាស់ចោល ហើយចូលព្រះវិហារយ៉ាងទៀងទាក់ទោះបីគេមិនទាន់ទទួលអគ្គសញ្ញាជ្រមុជទឹក តែពួកគោនកំណត់ ខ្លួនគេថាជាគ្រីស្តបរិស័ទរួចហើយ។

ក្នុងច្បាប់របស់ព្រះសហគមន៍កាតូលិក គឺតម្រូវឲ្យអ្នកឈ្វេងយល់ជំនឿទទួលការអប់រំជំនឿមួយរយៈសិន មុននឹងទទួលអគ្គ-សញ្ញាជ្រមុជទឹក ដោយមានតាមដំណាក់កាល យ៉ាងហោចណាស់១ឆ្នាំ។

ចំពោះការអប់រំជំនឿនេះ លោកបូជាចារ្យ ហ្វ្រង់ស្វ័របានបញ្ជាក់ថា គឺត្រូវអប់រំតាមដំណាក់កាល តែមិនអាចអនុវត្តតាមសៀវ-ភៅដែលបានរៀបចំដោយ ការិយាល័យអប់រំជំនឿកាតូលិកកម្ពុជាឡើយ ព្រោះពួកគាត់ជាច្រើននាក់មិនចេះអាន ហើយសៀវភៅនោះទៀតសោតមិនស៊ីគ្នានឹងបទពិសោធន៍របស់ពួកគេ ព្រោះភាគច្រើនទាក់ទងនឹងព្រះពុទ្ធសាសនា។ លោកថាការអប់រំជំនឿត្រូវធ្វើបន្ទាប់ពីការអធិដ្ឋាន ឬអភិបូជា គឺប្រើអត្ថបទព្រះបន្ទូលថ្ងៃអាទិត្យ ដើម្បីបង្រៀនគេបន្ថែម។

សមាគមគម្ពីរកម្ពុជាបានផលិតព្រះគម្ពីរជាភាសាពូណង សម្រាប់គ្រីស្តបរិស័ទទាំងអស់ ហេតុនេះព្រះសហគមន៍ក៏ប្រើព្រះគម្ពីរនោះដែរ។

ព្រះសហគមន៍កាតូលិកនៅមណ្ឌលគិរី បានខិតខំយកចិត្តទុកដាក់ បណ្តុះបណ្តាលឲ្យយុវជន យុវនារី ក៏ដូចកុមារាកុមារីបានទទួលការអប់រំ ចំណេះដឹងទូទៅ តាំងពីថ្នាក់មត្តេយ្យ រហូតដល់ថ្នាក់ឧត្តមសិក្សា។

មានតែការអប់រំទេ ដែលអាចជួយឲ្យគេធ្វើសមាហរណកម្មជាមួយសហគមន៍ខ្មែរ និងស្របតាមការវិវត្តរបស់សង្គមរស់នៅរបស់គេបាន។

ការសរសេរភាសាពូណងត្រូវយកអក្សរខ្មែរជាគោល ហេតុនេះពួកត្រូវតែចេះអាន និងសរសេរភាសាខ្មែរ។

ព្រះសហគមន៍កាតូលិកបានកើតនៅតំបន់ខេត្តមណ្ឌលគិរីដោយសារ ការភៀសខ្លួនក្នុងពេលមានសង្គ្រាម ក្នុងទសវត្ស ១៩៧០។ ពួកគេបានភៀសខ្លួនទៅប្រទេសវៀតណាម ហើយបានទទួលជឿលើព្រះយេស៊ូនៅទីនេះ រហូតដល់ឆ្នាំ ១៩៨៥ បានត្រលប់មកទឹកដីកម្ពុជាវិញ ដោយពួកគេតាំងទីលំនៅ នៅប៊ូស្រា និងដាក់ដាំ។ គេរស់នៅក្នុងជំនឿកាតូលិកជានិច្ចទោះបីពេលនេះគ្មានលោកបូជាចារ្យក៏ដោយ ដោយពួកគេចុះឡើងទៅប្រទេសវៀតណាម ក្នុងពេលបុណ្យធំៗ។ នេះតាមករៀបរាប់របស់លោក សាលី និងលោកត្រេ។ ចំពោះបងប្អូនចំណូលថ្មីដែលបានប្តូរជំនឿ គឺព្រោះតែការបង្ហាញសេចក្តីស្រលាញ់របស់គ្រីស្តបរិស័ទចំពោះពួកគេពេលគេមានធុរៈ និងជំងឺ។ នេះបើការរៀបរាប់របស់បងប្អូននៅកែវសីមា។



លោកបូជាចារ្យហ្វ្រង់ស្វ័រ អេមេល្យដាលបាននៅជាមួយយុវជន និងគ្រីស្តបរិស័ទដែលជាហ្វូងចៀមរបស់លោក ក្នុងជីវិតជាសាសនទូត។ លោកថានៅក្នុងបេសកកម្មនៅមណ្ឌលគិរីជាអ្វីមួយថ្មី និងបរិយាកាសថ្មីដែលលោកត្រូវរៀនឡើងវិញស្ទើរគ្រប់យ៉ាង។ លោកនៅជាមួយយុវជន ទៅចំការជាមួយប្រជាជន ដើរសួរសុខទុក្ខពួកគេតាមផ្ទះ ទំនាក់ទំនងជាមួយមនុស្សផ្សេងៗយ៉ាងស្និទស្នាល។ លោកអាចប្រើភាសាពូណងយ៉ាងស្ទាត់ ក្នុងការទាក់ទងជាមួយគេ រួមទាំងទេសនាផង។ ការធ្វើដំណើរពីមួយកន្លែងទៅមួយកន្លែងត្រូវប្រើពេលវេលាយូរបន្តិច ព្រោះទីកន្លែងនីមួយៗនៅឆ្ងាយៗពីគ្នា តែទោះយ៉ាងណាផ្លូវធ្វើដំណើរបច្ចុប្បន្នបានប្រសើរឡើងហើយ។



នៅទីរួមខេត្តក៏មានកូនព្រះវិហារតូចមួយដើម្បីជួបជុំគ្នា សម្រាប់យុវសិស្សដែលមករៀននៅទីរួមខេត្ត ដោយមានក្រុមបព្វជិត បងប្រុសម៉ារីស្តជាអ្នកជួយថែរក្សា។

ព្រះសហគមន៍កាតូលិកតំបន់ខេត្តមណ្ឌលគិរី មានជីវិតរស់រវើក មានកម្លាំងព្រមគ្នាទាំងយុវជន និងមនុស្សពេញវ័យក្នុងការជ្រោមជ្រែងទាំង ក្នុងពិធីបុណ្យ ការអប់រំជំនឿ កម្មវិធីអប់រំចំណេះទូទៅ និងសង្គហៈដែលជាសកម្មភាពមេត្តាករុណា៕













# កម្ពុជានឹងមានឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់

ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ នឹងត្រូវបង្កើតឡើងនៅពេលខាងមុខក្រោយជំនួបរវាង សម្តេចតេជោ ហ៊ុន សែន ជាមួយតំណាងគណបក្សនយោបាយចំនួន១៦ នៅព្រឹកថ្ងៃ ទី២១ ខែសីហា ឆ្នាំ២០១៨ នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់មួយ។

យោងទៅតាមសេចក្តីប្រកាសនៅលើបណ្តាញសង្គមផ្លូវការរបស់សម្តេចតេជោ ហ៊ុន សែន បានឲ្យដឹងថា សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបានជួបពិភាក្សាការងារជាមួយតំណាងគណបក្សនយោបាយដែលបានចូលរួមបោះឆ្នោត កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ កន្លងមកនេះ ចំនួន១៦ គណបក្ស ដែលធ្វើឡើងនៅវិមានសន្តិភាព រាជធានីភ្នំពេញ។

ក្នុងកិច្ចប្រជុំពិគ្រោះយោបល់នេះ សម្តេចតេជោ បានលើកឡើងថា ការបោះឆ្នោតបានកន្លងហើយ ទុកបញ្ហានោះមួយអន្លើ ហើយកម្ពុជាអាចចូលរួមកសាងប្រទេសជាតិជាមួយគ្នា ដោយមិនយូរប៉ុន្មានទេ "ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅ២០២២ និងការបោះឆ្នោតជាតិ ២០២៣ នឹងមកដល់" ការអញ្ជើញជួបជុំនេះ គឺមិនមែនមកគាំទ្រគោលការណ៍នយោបាយគណបក្សប្រជាជនកម្ពុជានោះទេ "ហើយមិនមែនជាផលប្រយោជន៍របស់រាជរដ្ឋាភិបាលនោះដែរ ប៉ុន្តែជាផលប្រយោជន៍ប្រជាពលរដ្ឋ"។

ប្រភពដដែលបានបន្តថា នាឱកាសនោះសម្តេចតេជោ ហ៊ុន សែន បានផ្តួចផ្តើមគំនិត និងពន្យល់ពីហេតុផលនៃការបង្កើត "ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់" ដែលជាយន្តការចូលរួមឆ្លើយតប និងផលប្រយោជន៍ប្រជាពលរដ្ឋ។ យន្តការនេះអាចហៅកាត់ថា "ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោប"។

ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់នេះមានភារកិច្ចដូចខាងក្រោមមួយចំនួន ដូចជា ផ្តួចផ្តើមគំនិត ឬផ្តល់មតិ នៅលើការរៀបចំគោលនយោបាយដល់រាជរដ្ឋាភិបាល, ចូលរួមផ្តល់យោបល់ដល់សេចក្តីព្រាងច្បាប់របស់រាជរដ្ឋាភិបាលមុនគណរដ្ឋមន្ត្រីអនុម័ត ហើយឧត្តម ក្រុមប្រឹក្សានេះមាន អាណត្តិ ធ្វើញាត្តិជូនព្រឹទ្ធសភាតតាំង និងច្បាប់ដែលបានអនុម័តដោយរដ្ឋសភាផងដែរ, ឧត្តមក្រុមប្រឹក្សានេះនឹងចូលរួមផ្តល់យោបល់ដល់នាយករដ្ឋមន្ត្រីចំពោះភាពអសកម្ម ឬបទរំលោភណាមួយរបស់មន្ត្រី ឬនាយករដ្ឋមន្ត្រី។

ប្រភពដដែលបានបន្តថា ការបង្កើតឧត្តមក្រុមប្រឹក្សានេះ គឺតាមរយៈព្រះរាជក្រឹត្យ។ សម្រាប់សមាសភាព និងយន្តការនៃការបង្កើតឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់នេះមាន៖ ១)សមាសភាពដោយស្ម័គ្រចិត្ត មកពីគណបក្ស ដែលបានចូលរួមបោះឆ្នោត អាណត្តិទី៦ ជាមួយនឹងការឯកភាពពីនាយករដ្ឋមន្ត្រី។ ២)គណបក្សនីមួយៗមានតំណាង០២រូប ដែលជាប្រតិភូ និងតែងតាំង ដោយព្រះរាជក្រឹត្យស្នើដោយនាយករដ្ឋមន្ត្រី ៣)ប្រធានឧត្តមក្រុមប្រឹក្សា គឺអនុវត្តន៍បាន គោលកាណ៍បន្តវេនមួយខែម្តងតាមលេខរៀង បញ្ជីបោះឆ្នោត។ ៤)ត្រូវមានលេខាធិការដ្ឋានមួយ ទទួលខុសត្រូវដោយមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និងមន្ត្រីម្នាក់មកពីគណបក្សនីមួយៗ ៥)លេខាធិការដ្ឋាន និងកន្លែងប្រជុំស្ថិតនៅក្នុង វិមានសន្តិភាព។

ប្រភពដដែលបានបន្តថា ជាមួយគ្នានោះ កិច្ចដំណើរការ នៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់នេះគឺ ប្រជុំមួយខែម្តង តាមការកោះប្រជុំរបស់ប្រធានបន្តវេន, ប្រជុំជាមួយនាយករដ្ឋមន្ត្រី ៦ខែម្តង ឬជាការចាំបាច់របស់នាយករដ្ឋមន្ត្រីដែលធ្វើនៅចន្លោះពេលនេះ តាមការកោះប្រជុំរបស់នាយករដ្ឋមន្ត្រី, ឧត្តមក្រុមប្រឹក្សាពិគ្រោះយោបល់នេះ នឹងត្រូវបញ្ចប់អនុលោមតាមអាណត្តិរបស់រាជរដ្ឋាភិបាល។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា "ឧត្តមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់" គឺជាយន្តការថ្មីមួយទៀត ដើម្បីចូលរួមឆ្លើយតប នឹងផ្តល់ផលប្រយោជន៍ប្រជាពលរដ្ឋទាំងមូល ដែលវាមិនមែនជាប្រយោជន៍របស់រាជរដ្ឋាភិបាលនោះឡើយ ហើយនេះជាការបើកទំព័រប្រវត្តិសាស្ត្រថ្មីមួយទៀត ដើម្បីផលប្រយោជន៍ប្រជាជាតិកម្ពុជាទាំងមូល។

វេទិកាពិគ្រោះយោបល់ថ្ងៃនេះ មានគណបក្សនយោបាយចូលរួមចំនួន១៦ ដែលរួមមាន គណបក្សខ្មែររួបរួមជាតិ, គណបក្សពន្លឺថ្មី, គណបក្សសញ្ជាតិកម្ពុជា, គណបក្សខ្មែរក្រោក, គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ, គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ, គណបក្សសាធារណរដ្ឋខ្មែរ, គណបក្សរស្មីខេមរា, គណបក្សហ៊្វុនស៊ិនប៉ិច, គណបក្សខ្មែរអភិវឌ្ឍសេដ្ឋកិច្ច, គណបក្សយុវជនកម្ពុជា, គណបក្សធម្មាធិបតេយ្យ, គណបក្សឆន្ទៈខ្មែរ, គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា, គណបក្សខ្មែរតែមួយ, និងគណបក្សប្រជាជនកម្ពុជា។ ដោយឡែកគណបក្សដែលមិនចូលរួមគឺមាន គណបក្សប្រជាធិបតេយ្យមូលដ្ឋាន, គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ, គណបក្សខ្មែរឈប់ក្រ, និងគណបក្សមាតុភូមិយើង។

គួររំលឹកថា នៅក្នុងដំណើរការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអណត្តិទី៦ កាលពីថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៨ មានគណបក្សចូលរួមទាំងអស់ចំនួន ២០ គណបក្ស ប៉ុន្តែមានតែគណបក្សប្រជាជនកម្ពុជា តែមួយគត់ ដែលទទួលបានអាសនៈនៅក្នុងសភា ដែលមានទាំងអស់១២៥ អសនៈ។ តាមសេចក្តីប្រកាសព័ត៌មានរបស់គណកម្មការធិការជាតិរៀបចំការបោះឆ្នោតបានឲ្យដឹងថា នៅក្នុង ចំណោមតំណាងរាស្ត្រទាំង ១២៥ រូបដែលបានជាប់ឆ្នោតនោះ គឺមានស្ត្រី ១៩រូប ហើយតំណាងរាស្ត្រ ដែលមានអាយុចំណាស់ជាងគេ គឺ អាយុ ៨៤ឆ្នាំ ខណៈដែលក្មេងជាងគេ នោះ គឺអាយុ ៣២ ឆ្នាំ ។

ការបោះឆ្នោតនោះ គឺមានការចូលរួមដោយអ្នកសង្កេតការណ៍ នៅក្នុងស្រុក ៧៩.៦១២នាក់ មកពី ១១២ស្ថាប័ន អ្នកសង្កេតការណ៍អន្តរជាតិ ៥៣៩នាក់ មកពី ៧០ស្ថាប័ន និងស្ថានទូតនានា នៅកម្ពុជា និងអ្នកសង្កេតការណ៍តំណាងគណបក្សនយោបាយចំនួន ប្រមាណជា ៧៩.៨៤៩ នាក់។

ការបោះឆ្នោតកាលពីឆ្នាំ២០១៣ គឺគណបក្សប្រជាជនកម្ពុជាទទួលបានសំឡេងឆ្នោត ៣,២៣លាន សន្លឹក ដោយទទួលបាន ៦៨អាសនៈ ហើយគណបក្សសង្គ្រោះជាតិទទួលបាន ២,៩លានសន្លឹក ឬ៥៥អាសនៈ ប៉ុន្តែគណបក្សនេះត្រូវបានតុលាការកំពូលប្រកាសរំលាយចោលដោយរំលោភច្បាប់៕

*ដោយ អរិយបុត្រ*



*រូបភាពពីហ្វេសបុក សម្តេចតេជោ ហ៊ុន សែន*

# យុវជនថា ការផ្សព្វផ្សាយពីសិល្បៈគឺច្រើននិងទូលំទូលាយ




រូបភាពពីហ្វេសបុក The Voice Kids Cambodia

ការងារនៅក្នុងសង្គមគឺមានច្រើន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយការងារដែលពាក់ព័ន្ធនឹងសិល្បៈគឺមានការផ្សព្វផ្សាយបានច្រើននិងទូលំទូលាយច្រើនជាងការងារនៅក្នុងវិស័យផ្សេងៗទៀត។ នេះបើតាមការកត់សំគាល់របស់យុវសិស្ស និងយុវនិស្សិតមួយចំនួន ។

យុវសិស្ស ស៊ុន ស្រីណែត ដែលជាសិស្សថ្នាក់ទី១១មួយរូប បានអះអាងទាំងនៅក្នុងសម្លៀកបំពាក់ជាសិស្ស នៅមុំសាលាបាក់ទូក ថានាងចូលចិត្តមើលទូរទស្សន៍ ប៉ុន្តែកម្របានឃើញកម្មវិធីទូរទស្សន៍និយាយអំពីការងារផ្សេងៗនៅក្នុងសង្គមណាស់ ។

ស្រីណែត បានបញ្ជាក់ថា "ដូចអត់ដែលមានកម្មវិធីការងារអីផ្សេងផង ខ្ញុំឃើញដូចជា ព័ត៌មាន ភាពយន្ត និងចម្រៀងអីហ្នឹង តែខ្ញុំមើលតែ រឿង និងចម្រៀង ជួនកាល គឺកម្មវិធីកម្សាន្តខ្លះដែរ"។

យុវសិស្សវិទ្យាល័យមួយរូបទៀត បានអះអាងថា រូបគេមិនដឹងជាមើលអី នៅក្នុងកម្មវិធីទូរទស្សន៍ សព្វថ្ងៃនេះ ដោយភាគច្រើន វាដដែលៗ ចឹងហើយ បានជាមិនដឹងមើលអី ។

យុវសិស្ស ផាន់ បញ្ញាសិទ្ធិ បានអះអាងថា អាណាព្យាបាលរបស់ប្អូន មិនសូវអនុញ្ញាតឲ្យប្អូនមើលទូរទស្សន៍នៅក្នុងស្រុកឡើយ ដូច្នេះ ទើបបានមិនសូវដឹងអី ។

បញ្ញាសិទ្ធិ បានអះអាងថា "មិនដឹងទេបង (អ្នកយកព័ត៌មានអ្នកនាំសារ ) ខ្ញុំមិនសូវបានមើលទូរទស្សន៍ផង ដោយសារតែរៀន ហើយពេលទំនេៗ ប៉ាម៉ាកឲ្យមើលតែកម្មវិធី ទូរទស្សន៍បរទេស ដូចជាកម្មវិធី ឌិ-ស្គូវើរី ណេសូណលជីអូហ្គ្រាហ្វិអីហ្នឹង។ ពួកគាត់ប្រាប់ថា ទូរទស្សន៍ខ្មែរ មានតែរឿង មានតែចម្រៀង មានតែកម្សាន្ត ។ ទាល់តែយូៗបានគាត់ឲ្យមើលម្តង ដូចជាកម្មវិធីប្រឡងចម្រៀង The Voice កម្មវិធី Cambodia Got Talent ជាដើម ប៉ុន្តែមិនជាច្រើនទេ ត្រឹមម៉ោង១០: ៣០អី ឈប់ហើយ"។

យុវនិស្សិត ទេព កោសល្យ ដែលកំពុងសិក្សាថ្នាក់បរិញ្ញាប័ត្រព័ត៌មានវិទ្យា មួយរូប បានឲ្យដឹងថា តាមដែលរូបគេដឹងនឹងបានមើលខ្លះៗ គឺថា កម្មវិធីទូរទស្សន៍ដូចជា អត់មានកម្មវិធីនិយាយអំពី វិស័យការងារមានតែកម្មវិធីកម្សាន្ត កម្មវិធីចំណេះដឹងទូទៅព័ត៌-មានអីហ្នឹង ដោយឡែកកម្មវិធីកម្សាន្តគឺច្រើនតែម្តង ប៉ុស្តិ៍ណាក៏មានដែរឥឡូវនេះ។

កោសល្យ បានអះអាងថា រហូតមកដល់ពេលនេះ រូបគេកម្រមើលទូរទស្សន៍ណាស់ ដោយភាគច្រើន គឺគេមើលតែយូធូប។

កោសល្យបានបញ្ជាក់ថា "កម្មវិធីទូរ-ទស្សន៍ វិទ្យុអី ភាគច្រើន វាដដែលៗ ខ្ញុំមិនសូវមើលទេ។ វាដូចជាសុំា អត់មានអីប្លែក មានតែកម្មវិធីកម្សាន្ត ចម្រៀង... ចឹងហើយ បានខ្ញុំមើលយូធូប (youtube) ស្អីក៏មានដែរ ខ្ញុំចង់មើលពីការពិភាក្សា អំពីប្រធានបទ Assignment ( កិច្ចការសាលា ) អំពីអាស៊ាន អំពីវិស័យការងារ គឺមានបើឲ្យមើលទូរ-ទស្សន៍ ស្តាប់វិទ្យុចប់ហ្មង"។

យុវនិស្សិត ដួង ទេវិន ដែលកំពុងតែសិក្សាជំនាញ ពាណិជ្ជកម្មអន្តរជាតិបាន អះអាងថា ទូរទស្សន៍ និងវិទ្យុខ្មែរយើង មាន ច្រើន ដែរ ប៉ុន្តែ កម្មវិធីដូចជា សុំា ដដែលៗ អត់សូវមានអីទាក់អារម្មណ៍ ។

ទេវិន បានអះអាងថា ទូរទស្សន៍យើង ច្រើន តែកម្មវិធីល្អៗ ដែលមានប្រយោជន៍ ដូចជាមិនសូវមាន។ កម្មវិធីល្អៗមានដូចជា កម្មវិធីជជែកពិភាក្សារឿងអីមួយ កម្មវិធី ជជែកអំពីអាស៊ាន ប៉ុន្តែវាតិចពេក ដោយ ភាគច្រើន បើកទៅ គឺមានតែកម្មវិធីចម្រៀង កុន កម្សាន្ត និងព័ត៌មាន ហើយព័ត៌មាន ទៀតសោត គឺដូចជា រីងៗអាម៉េចទេ។

អាណាព្យាបាលមួយរូប ដែលអះអាង ប្រាប់ថា គឺជាអាណាព្យាបាលយុវជន២រូប បានអះអាងថា តាំងពីក្មេងមក ដល់កូនៗ លោករៀនវិទ្យាល័យ និងអនុវិទ្យាល័យមក នេះ លោកមិនសូវអនុញ្ញាតឲ្យកូនមើល កម្មវិធី ទូរទស្សន៍ នៅក្នុងស្រុកណាស់ ដោយ សារតែ ខ្លាចកូនដុះតែរឿង អត់ប្រយោជន៍ ច្រើន។

លោកបានបន្ត ទូរទស្សន៍នៅក្នុងស្រុក មានច្រើនណាស់ ប៉ុន្តែមិនសូវមានកម្មវិធី មានប្រយោជន៍ សម្រាប់ក្មេង ណាស់ គឺភាគ ច្រើនមានតែកម្មវិធីរាំច្រៀង កម្មវិធីកម្សាន្ត ច្រើន រីឯកម្មវិធីល្អៗមានដែរ ប៉ុន្តែវាតិច ។

លោកបានបញ្ជាក់ថា "កូនខ្ញុំតាំងពីតូច មក ខ្ញុំមិនសូវទម្លប់ឲ្យកូន មើលកម្មវិធីប្រឡង ចម្រៀង កម្មវិធីប្រឡងរាំ ហើយទូរទស្សន៍ យើងសំបូរអាហ្នឹង សំបូរអាកម្មវិធីចឹងៗច្រើន ហើយឥឡូវ ពួកគេ មិនមើលតែម្តងកម្មវិធី អស់ហ្នឹង"។

លោក លឹម ពិទូរ ដែលជាប្រជាពលរដ្ឋ វ័យ ៤៨ឆ្នាំ មួយរូប បានឲ្យដឹងថា មកដល់ ពេលនេះ ដើម្បីលើកទឹកចិត្ត ក៏ដូចជាបណ្តុះ ទឹកចិត្តក្មេងៗ ទូរទស្សន៍ ឬក៏វិទ្យុគួរតែមាន កម្មវិធីណែនាំឲ្យក្មេងៗស្គាល់ពីការងារ។

តាមការពន្យល់ របស់លោក ពិទូរ គឺថា ទូរទស្សន៍ គួរតែមានកម្មវិធីមួយដែលអាច ណែនាំឲ្យក្មេងៗ គាត់ស្គាល់ ឧទាហរណ៍ ការងាររដ្ឋបាល គឺធ្វើយ៉ាងម៉េចគ្រូ គេធ្វើ យ៉ាងម៉េចមានតម្លៃម៉េច... ប៉ុន្តែដូចជាអត់ មាន បើមាន គឺមានតែការងារជាអ្នកចម្រៀង ការងារជាសិល្បៈសម្តែងតែប៉ុណ្ណឹង។

លោកបានបន្តទៀតថា ប្រសិនជាយើង មានកម្មវិធីបែបនេះ ប្រហែលជាល្អ ពីព្រោះ វាជួយបណ្តុះទឹកចិត្ត និងជួយឲ្យក្មេងៗ ស្គាល់ពីការងារ យល់ពីការងារ ដើម្បីជា ការផ្តល់ការរិះគិតដល់ពួកគេ ប៉ុន្តែ លោក ក៏បានបន្ទោស អ្នកទស្សនា ពោលគឺអ្នក មើលនៅក្នុងស្រុកនេះផងដែរថា ភាគច្រើន ប្រជាពល រដ្ឋយើងមានការយល់ដឹងទាប ដូច្នេះមិនសូវជាចូលចិត្តកម្មវិធីបែបនេះទេ។

លោក ពិទូរ បានអះអាងបញ្ជាក់ថា "បន្ទោស បណ្តាប៉ុស្តិ៍ទូទស្សន៍ ទាំងនេះ ទាំងអស់ក៏មិនកើតដែរ។ ភាគច្រើនអ្នក មើលនៅស្រុកយើង មិនចូលចិត្តអាកម្មវិធី មានប្រយោជន៍ទេ គឺចូលចិត្តតែកម្មវិធី កម្សាន្តបែបហ្នឹង បានជា ទូរទស្សន៍ផ្សេងៗ គាត់គិតតែប្រឡងប្រណាំងគ្នា តែពីការ ផលិតកម្មិវធី កម្សាន្តបែបនេះ"។

មកដល់ពេលនេះកម្ពុជាត្រូវបានគេដឹង ថា មានស្ថានីយទូរទស្សន៍នៅក្នុងស្រុក ប្រមាណជា ២១ ស្ថានីយ ក្រៅពីនោះនៅ មានទូរទស្សន៍អនឡាញ ទូរទស្សន៍បង់លុយ វិទ្យុជាង ២០០ ស្ថានីយថែមទៀត៕

*ដោយ អរិយបុត្រ*

# កម្មករ និងកម្មការិនីវិស័យកាត់ដេរកំពុងតែរង់ចាំការសន្យារបស់គណបក្សឈ្នះឆ្នោត



រូបភាពពីហ្វេសបុក សម្តេចតេជោ ហ៊ុន សែន

បណ្តាកម្មករ និងកម្មការិនីនៃវិស័យឧស្សាហកម្មកាត់ដេរនៅក្នុងប្រទេសនៅពេលនេះកំពុងតែរង់ចាំ មើលការអនុវត្តរបស់រាជរដ្ឋាភិបាលថ្មីដែលនឹងដឹកនាំនាវាកម្ពុជា៥ ឆ្នាំទៅមុខទៀតក្រោយពេលដែលគណបក្សកាន់អំណាចនេះបានសន្យានឹងពួកគេ។

ឡេង លក្ខិណា ជាកម្មការិនីរោងចក្រកាត់ដេរ មួយកន្លែងនៅម្តុំទួលសង្កែ និងជាកម្មការរនីមួយរូប ដែលមានទីលំនៅនៅខេត្តកំពង់ឆ្នាំង បាននិយាយថា ប្រមុខគណបក្សកាន់អំណាចបានសន្យាច្រើនណាស់ជាមួយនឹងកម្មករ កាលពីមិនទាន់បានបោះឆ្នោត ចាំមើលថា តើគាត់នឹងធ្វើបានប៉ុណ្ណា។ ប៉ុន្តែ ប្រសិនបើគាត់អាចធ្វើបាន នោះប្រសើរមែនទែនសម្រាប់កម្មករ និងកម្មការិនី ដូចជាពួកនាង។

លក្ខិណា បានបញ្ជាក់ថា "សម្តេច ហ៊ុន សែន និយាយច្បាស់ណាស់ថា នៅឆ្នាំ២០១៩នេះ យើងនឹងមាន ប្រាក់រឹត្រែតដូចមន្ត្រីរាជការ ប៉ុន្តែអ្នកខ្លះថា ពិបាកធ្វើណាស់"។

តាមការអះអាងរបស់ លក្ខិណា ប្រមុខគណបក្សកាន់អំណាច ដែលទើបតែនឹងបន្តឈ្នះនៅក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រអណត្តិទី៦ កាលពីថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៨ កន្លងទៅនេះ នៅបានសន្យាចំណុចជាច្រើនទៀត រួមទាំងសម្រាលកូន រឿងតម្លើងប្រាក់បៀវត្ស រឿងសុខុមាលភាព រឿងថ្លៃទឹកថ្លៃភ្លើង រឿងផ្ទះជួល ។ល។

លក្ខិណា បានបញ្ជាក់ទៀតថា "កាលពេលដែលខ្ញុំបានជួបគាត់នៅកម្មវិធីប៉ុន្មានខែមុនបោះឆ្នោត សម្តេច ហ៊ុន សែន គាត់និយាយច្រើន រឿងកម្មករ តែខ្ញុំចាំបានខ្លះៗជាពិសេស អារឿងកើតកូន រឿងតម្លើងប្រាក់ខែ រឿងទៅពេទ្យ អត់យកលុយអីហ្នឹង។

នៅក្បែរនឹងលក្ខិណា អ្នកនាង សៅ វ៉ាន់ថា ដែលជាកម្មការិនីរោងចក្រ និងជាមិត្តនឹងកញ្ញា លក្ខិណា បានបន្ថែមទៀតថា ប្រមុខគណបក្សប្រជាជនកម្ពុជា បានមានប្រសាសន៍ច្រើននៅពេលជួបកម្មករម្តងៗ ប៉ុន្តែ ឃើញថា ម៉ាចំនួន សម្តេចបានធ្វើបានហើយ ។

វ៉ាន់ថា បានបន្តថា រឿងភ្លើង រឿងទឹក រឿងផ្ទះជួល រឿងទៅពេទ្យអត់យកលុយ រឿងជួយសម្រួលរឿងពិនិត្យសុខភាពអី គឺឃើញថា យើងអាចទទួលយកបាន ។

វ៉ាន់ថា បានបញ្ជាក់ថា "មុនបោះឆ្នោតខ្ញុំទៅពេទ្យ ឃើញថា អត់មានគេយកប្រាក់អីទេ ទោះពេល នោះ ខ្ញុំទៅមើលឈាមថតស្ទួត និងមើលអេកូ គ្រឿងក្នុងពីព្រោះចេះតែចុកពោះ... ពេទ្យគេអត់យកលុយទេ គឺខ្ញុំប្រើតែកាត ប.ស.ស"។

លោក រិន បញ្ញា ជាបុគ្គលិកផ្នែករដ្ឋបាលនៅរោងចក្រមួយ បានឲ្យដឹងថា ជាទូទៅប្រសិនបើរាជរដ្ឋាភិបាល ថ្មី គាត់អាចធ្វើបានទៅតាមប៉ុន្មានចំណុចដែលគាត់សន្យាចំពោះកម្មករគឺថា ល្អមែនទែន ។

លោកបានបន្តថា សូម្បីតែរូបលោកក៏រំភើបនឹងការសន្យានេះដែរ ពីព្រោះល្អ និងជួយសម្រួលជាច្រើនដល់កម្មករ និងកម្មការិនីនានា។

លោកបានបន្តទៀតថា សម្រាប់រឿងប្រាក់ខែ ១៧០ ដុល្លារនេះ វាមិនច្រើនតែប៉ុន្តែការដែលរដ្ឋាភិបាល បានធ្វើបាននេះគឺវាប្រសើរមួយដែរ ហើយរឿងផ្ទះជួលក៏ដូច្នេះដែរ ពីព្រោះដូចជា ប៉ុន្មានឆ្នាំ ហើយម្ចាស់ផ្ទះជួល ដូចជានៅមិនទាន់ហ៊ានតម្លើងថ្លៃជួលនៅឡើយទេ ហើយ រឿងដែលធូរគឺរឿងទៅ ពិនិត្យ សុខភាព ព្យាបាលជំងឺ គឺពិតជាសមស្របមែនទែន ។

លោកបានបញ្ជាក់ថា "ពីមុនកម្មករឈឺអី យើងជូនទៅពេទ្យ ពេលហុចកាត់ ប.ស.ស ទៅគេ! គេមិនចង់ទាំងនិយាយរកផង ប៉ុន្តែថ្មីៗនេះ អាចថា ជិតបោះឆ្នោតឬមិនដឹង ឃើញថា រាក់ទាក់ និយាយឲ្យចំគឺ ល្អខុសគ្នា ពីមុនដាច់តែម្តង"។

លោកបានថ្លែងបញ្ជាក់បន្តថា ប៉ុន្មានថ្ងៃមុនបោះឆ្នោត លោកបានជូនកម្មករ និងកម្មការិនី ៤ នាក់ទៅពេទ្យ រុស្ស៊ី ពេលទៅដល់ ឃើញថាសេវាកម្មគេល្អ ខុសប្លែកពីមុនបានន័យថា គេបានយកចិត្តទុកដាក់ ជួយសម្របសម្រួល និងពិនិត្យជូនពួកគេល្អ ហើយពួកគេមកវិញនិយាយថាសេវាសុខាភិបាលរដ្ឋគឺអាចទទួលយកបាន។

នៅក្នុងយុទ្ធនាការចុះជួបជាមួយកម្មករនិយោជិតនៅជុំទី២ ដែលបានចាប់ផ្តើមនាព្រឹកថ្ងៃទី០២ ខែសីហានេះ សម្តេចតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានស្នើឲ្យមន្ត្រីពាក់ព័ន្ធបន្តអនុវត្តន៍ឲ្យបានសកម្មថែមទៀតនូវអនុសាសន៍ ១០ ចំណុច ដែលបានដាក់ចេញការពីមុនពេលបោះឆ្នោត ក្នុងគោលដៅជំរុញការយកចិត្តទុកដាក់ចំពោះកម្មករ និងការអភិវឌ្ឍបន្តនូវគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥។

តាមសម្តេចតេជោ ហ៊ុន សែន ចំណុចទី១ ប្រាក់បៀវត្សរ៍ទាបបំផុ ១៧០ ដុល្លារ ហើយចំណុចថ្មី គឺបើកប្រាក់ខែពីរអាទិត្យម្តង។ ទី២ បន្តពិនិត្យឲ្យបានជិតដល់ការពិនិត្យ និងព្យាបាលជំងឺជូនកម្មករកម្មការិនីដោយមិនគិតថ្លៃ។ ទី៣ ត្រូវតាមដានពិនិត្យមើលការអនុវត្តចំពោះកម្មការិនីដែលមានផ្ទៃពោះ និងឆ្លងទន្លេត្រូវទទួលបានប្រាក់ខែ១២០%ជាមួយនឹងការសម្រាក ៣ខែ ដោយមានប្រាក់ខែ។ ទី៤ ត្រូវតាមដានមើលការបើក សាច់ប្រាក់ជូនកម្មការិនីដែលឆ្លងទន្លេ។ មកដល់ពេលនេះមានកម្មការិនីឆ្លងទន្លេប្រមាណជាង ៣៣.០០០ នាក់ហើយ។ ឆ្នាំនេះគ្រោងទុកក្នុងថវិកាជាតិ ១០លានដុល្លារ តែមកដល់ពេលនេះយើងចាយទើបតែអស់ប្រមាណ ៣លានដុល្លារប៉ុណ្ណោះ។ ទី៥ ត្រូវខិតខំពិនិត្យមើលការបង់ធានារ៉ាប់រងសម្រាប់សុខភាពចំពោះកម្មករនិយោជិត ។ ទី៦ នៅត្រួតពិនិត្យជាប្រចាំនូវការអនុវត្តថ្លៃឈ្នួលទឹកជ្រោះភ្លើង និងឈ្នួលផ្ទះ។ ថ្លៃភ្លើងបានចុះថែមទៀតហើយ និងត្រូវចុះថែមទៀតនៅក្នុងឆ្នាំ ២០១៩ ។ ឆ្នាំ២០២០ និងគ្រប់ឃុំទាំងអស់ទូទាំងប្រទេសត្រូវតែមានបណ្តាញអគ្គីសនីរដ្ឋទៅដោយឲ្យតម្លៃភ្លើង និងបន្តចុះថោកថែមទៀត។ទី៧ ខិតខំធ្វើឱ្យកម្មករកម្មការិនី និងនិយោជិតទទួលបានប្រាក់សោធននិវត្តន៍នៅពេលចាស់ដែលនឹងចាប់ផ្តើមនៅក្នុងឆ្នាំ២០១៩ នេះ។ ដូចនេះក្មួយៗ ត្រូវរក្សាទុកនូវសៀវភៅការងាររបស់ខ្លួន រយៈពេល ១០ឆ្នាំ ។ ៨ ត្រូវខិតខំដោះស្រាយចំពោះករណីម្ចាស់រោងចក្ររត់ចោលកម្មករដែលរហូតមកដល់ពេលនេះរដ្ឋាភិបាលចំណាយ ២២ លានដុល្លាររួចមកហើយ។ ប្រាក់អតីតភាពការងារត្រូវបើកខាងកម្មករក្នុងរយៈពេល ១ខែម្តង ដើម្បីជៀសវាងថៅកែរត់ចោលកម្មករ ។ទី៩ ការយកចិត្តទុកដាក់ទៅលើសុវត្ថិភាពក្នុងការដឹកជញ្ជូនកម្មករនេះជារឿងមួយថ្មីនៅក្នុងចំណោមរឿងដែលយើងត្រូវយកចិត្តទុកដាក់។ ទី១០ ត្រូវបន្តដោះស្រាយពលករដែលកំពុងធ្វើការនៅក្រៅប្រទេស ហើយយើងបានបញ្ចប់រួចរាល់ហើយចំពោះបងប្អូនកម្មករនៅក្នុងប្រទេសថៃ៕

ដោយ អរិយបុត្រ

# កិច្ចការទាមទាមឋានៈ៖ ជាមរណសាក្សីនៅប្រទេសកម្ពុជាកំពុងតែដំណើរការទៅមុខ



លោកបូជាចារ្យ ប៉ុល ឡឿង ឆ័ត្រស៊ីរី

*ដើម្បីឲ្យដឹងច្បាស់ថា តើមកដល់ពេលនេះ ដំណើរការទាមទារឋានៈជាមរណ-សាក្សីនៅប្រទេសកម្ពុជា ជូនបុព្វការីនៃព្រះសហគមន៍កាតូលិកនៅកម្ពុជាដើរដល់កម្រិតណានោះ លេខនេះអ្នកនាំសារសូមណែនាំ មិត្តអ្នកអានឲ្យជួបជាមួយនឹងលោក បូ. ឆ័ត្រស៊ីរី ដែលជាអ្នកទទួលកិច្ចការនេះ។*

**អ្នកនាំសារ ៖** កាលពីថ្ងៃទី៨ ដល់ថ្ងៃ១៣ ខែមិថុនា កន្លងទៅ លោកពុកបានអញ្ជើញទៅប្រជុំនៅទីក្រុងរ៉ូមផ្តោតសំខាន់ទៅលើ "មរណសាក្សីនៅទ្វីបអាស៊ី" ដូច្នេះ តើមានពាក់ព័ន្ធនឹងកិច្ចការមរណសាក្សីនៅកម្ពុជាដែរឬទេ ?

**បូ.ឆ័ត្រស៊ីរី ៖** បាទ! នៅកិច្ចប្រជុំនៅឯទីក្រុងរ៉ូម គឺផ្តោតទៅលើប្រធានបទ "មរណសាក្សីនៅទ្វីបអាស៊ី" ប៉ុន្តែ ប្រទេសដែលបានចូលរួម មាន៧ប្រទេស គឺប្រទេសវៀតណាម ថៃ ឡាវ កម្ពុជាយើង កូរ៉េខាងត្បូង ជប៉ុន និងប្រទេសមកពីអាស៊ីកណ្តាល។ ប្រទេសនីមួយៗក៏បានបញ្ជូនតំណាងរបស់ខ្លួន ដោយខ្លះជាបូជាចារ្យខ្លះជាគ្រហស្ថ ខ្លះជាអ្នកដែរធ្វើការទាក់ទងនឹងការស្រាវជ្រាវពីមរណសាក្សីនៅប្រទេសនីមួយៗ ។ សម្រាប់ប្រទេសកម្ពុជាយើងពិសេសជាងគេគឺដោយសារប្រទេសទាំងអស់មានរបាយការណ៍ និងសុទ្ធតែមានមរណសាក្សីជាផ្លូវការអស់ហើយ មានតែប្រទេសកម្ពុជាយើងប៉ុណ្ណោះ ដែលក្នុងដំណើរការសើបអង្កេត មានន័យថា កំពុងធ្វើសំណុំរឿងផ្ញើទៅក្រសួងមរណបុគ្គលដើម្បីពិចារណានាមរបស់យើងទាំងអស់ឈ្មោះនឹងថាជាមរណសាក្សីរបស់ប្រទេសកម្ពុជាយើង ដូចនេះមានតែប្រទេសកម្ពុជាយើងតែមួយទេដែលកំពុងដំណើរការនេះ។

**អ្នកនាំសារ ៖** តើព្រះសហគមន៍នៅប្រទេសកម្ពុជានឹងដាក់ឈ្មោះទាមទារឋានៈជាមរណសាក្សីប៉ុន្មាននាក់ទៅកាន់ក្រសួងសន្តបុគ្គលដើម្បីក្លាយទៅជាមរណសាក្សីនៅប្រទេសកម្ពុជា ?

**បូ.ឆ័ត្រស៊ីរី ៖** បាទ!ព្រះសហគមន៍នៅប្រទេសកម្ពុជារបស់យើងចាប់ពីពេលយើងចាប់ផ្តើមដំណើរការតុលាការនៅឆ្នាំ២០១៦ នោះយើងបានស្នើសុំចំនួន ៣៥នាក់ ប៉ុន្តែក្រោយបានដំណាក់កាល១ឆ្នាំកន្លងមក យើងឃើញថា ៣៥នាក់ទាំង អស់ដូចជាយើងមិនអាចទៅលឿន និងដូចជាខ្វះទិន្នន័យមួយចំនួនធំដែរ ហេតុដូច្នេះហើយខាងអង្គតុលាតាមរយៈលោកអភិបាលអូលីវីយេ បានសម្រេចចិត្តឲ្យបន្ថយឈ្មោះ ដើម្បីបន្តទៅមុខ។ សព្វថ្ងៃនេះយើងបានស្នើរក្នុងឈ្មោះអ្នកបម្រើព្រះជាម្ចាស់ដែលជាមរណ-សាក្សីរបស់ប្រទេសកម្ពុជា ចំនួន១៤នាក់ ដែលមកពីក្រុមផ្សេងៗនៅក្នុងព្រះសហ-គមន៍ក៏ដូចជាលោកអភិបាល បុព្វជិត បុព្វជីតា បងប្រុស បងស្រី បូជាចារ្យ និងគ្រហស្ថ។ ដូច្នេះទាំង១៤នាក់នឹងក្នុងពេលលោកពុកទៅសន្និសិទនេះក៏យកពេលទំនេរទៅណាត់ជួបខាងក្រសួងសន្តបុគ្គលដើម្បីបញ្ជូនឈ្មោះ១៤នាក់ នៅក្នុងលក្ខ-ខណ្ឌថា ១៤នាក់នេះគ្មានឧបសគ្គ ឬគ្មានបញ្ហាណាមួយរារាំងមិនអាចបន្តទៅមុខបាន ដូចនេះទាំង១៤នាក់នេះ លោកអភិបាលគាត់បានផ្ញើសំបុត្រតាមរយៈលោកពុកទៅក្រសួងសន្តបុគ្គលនៅក្នុងឱកាសនេះទៅរ៉ូមរួចរាល់។

**អ្នកនាំសារ៖** នៅក្នុងកិច្ចប្រជុំលើកនេះ តើមានការលើកទឹកចិត្តព្រះសហគមន៍កម្ពុជា ឬក៏កិច្ចការមរណសាក្សី នៅប្រទេសកម្ពុជា ឬទេ ?

**បូ.ឆ័ត្រស៊ីរី៖** បាទ! ដោយសារនៅក្នុងតំណាងរបស់ប្រទេសនីមួយៗគាត់បានមានបទពិសោធន៍ច្រើនក្នុងការងារមរណ-សាក្សី និងមានសុភមង្គល ឬក៏បុគ្គលនៅប្រទេសរបស់គេ ហើយជាពិសេសប្រទេសដែលទើបនឹងទទួលឈ្មោះមរណ-សាក្សីថ្មីៗនេះគឺប្រទេសឡាវ លោកពុកទទួលខុសត្រូវលើបន្ទុកការងារនឹងក្នុងការបង្រួបបង្រួមទិន្នន័យគឺលោកពុក ឆាកឡុទឡុង បានជួប និងជួយចែករំលែកបទ-ពិសោធន៍ធ្វើកន្លងមក។ ប្រទេសនីមួយៗក៏បានចែករំលែកអំពីជីវិតមរណសាក្សីដែរ តើមរណសាក្សីទាំងអស់នោះបានជំរុញជំនឿគ្រីស្តបរិស័ទតាមរយៈនីមួយៗនឹងយ៉ាងដូចម្តេច? នៅក្នុងអង្គប្រជុំនេះគេបានឲ្យយើងធ្វើរបាយការណ៍ ធ្វើសារណាខ្លីមួយជាង១០ទំព័រដើម្បីរិះគិតអំពីរឿងនេះ ដោយទី១ទាក់ទងនឹងជីវិតមរណ-សាក្សី ចំណែកទី២គឺសំខាន់មែនទែនគឺទាក់ទងនឹងជីវិតមរណៈសាក្សីទាំងនោះបានជាគំរូជួយជំរុញ មានឥទ្ធិពលទៅលើសង្គមជីវិតរស់នៅ ខាងសេដ្ឋកិច្ចនយោ-បាយរបស់ប្រទេសនីមួយៗ ដែលមានមរណសាក្សីទាំងនោះយ៉ាងដូចម្តេច?។ មានន័យថាតំណាងតាមប្រទេសនីមួយៗត្រូវតែរិះគិត និងស្រាវជ្រាវថា ឥទ្ធិពលខាងមរណសាក្សីនៅប្រទេសនីមួយៗនឹងបានទៅលើអ្នកមានជំនឿ ឬសង្គមជាតិរបស់ពួកគេយ៉ាងដូចម្តេចដែរ?។

**អ្នកនាំសារ ៖** មុននឹងបញ្ចប់សំនួរ តើលោកពុកមានអ្វីលើកទឹកចិត្តគ្រីស្តបរិស័ទដើម្បីឲ្យចូលរួមកិច្ចនៅក្នុងមរណសាក្សីនៅប្រទេសកម្ពុជានេះដែរទេ?

**បូ.ឆ័ត្រស៊ីរី ៖** បាទ! មរណសាក្សីនៅប្រទេសរបស់យើង យើងបានដាក់ថាជាលោកឆ្មា សាឡាស និងសហការី ១៣នាក់ទៀត។យើងដឹងហើយថាដំណើរការរបស់យើងគឺនៅក្នុងការសើបអង្កេត ហេតុដូច្នេះយើងនៅខ្វះសាក្សី ព័ត៌មាន ទិន្នន័យ និងឯកសារជាច្រើន ប្រសិនបើបងប្អូនស្គាល់អ្នកណាឬក៏អាចមានបទពិសោធន៍ជាមួយមរណសាក្សីទាំងអស់នោះផ្ទាល់ សូមជួយទាក់ទង និងបញ្ជូនព័ត៌មានឲ្យលោកពុកដើម្បីអាចឲ្យយើងប្រមូលទិន្នន័យ ឬសម្ភាសន៍រៀបចំឯកសារ ប្រមូលឯកសារទាំងអស់នោះមកដើម្បីចូលជាឯកសារដែរយើងបញ្ជូនទៅខាងក្រសួងសន្តបុគ្គល និងពិចារណាអំពីជីវិតរបស់ពួកគេបាន តែប្រសិនបើយើងអត់មានទេ និងជាការពិបាកមែនទែនដោយសារយើងខ្វះទិន្នន័យ ជាពិសេសសាក្សីបានមានបទពិសោធន៍ជាមួយពួកគេផ្ទាល់។ ប្រសិនបើបងប្អូនមានមិនថានៅប្រទេសកម្ពុជាយើងឬនៅក្រៅប្រទេស នៅវៀតណាម នៅឡាវ បារាំងវៀតណាម ឬក៏នៅប្រទេសណាដែលស្គាល់ បុគ្គលទាំង ១៤នាក់នេះសូមបងប្អូនជួយជូនព័ត៌មានខ្ញុំ ដែលជាបូជាចារ្យទទួលខុសត្រូវ។ នៅក្នុងឱកាសនេះដែរ ចំនុចទី២ គឺសូមបងប្អូនជួយអធិដ្ឋានសូមឲ្យមរណសាក្សីទាំងនោះជាគំរូល្អសម្រាប់យើង ភាពក្លាហានរបស់គាត់គឺពិតជានាំឲ្យយើងក្លាហាននៅក្នុងការរស់នៅក្នុងជីវិតសង្គមសព្វថ្ងៃនេះដែរ ទោះបីបរិយាកាសខុសគ្នាយ៉ាងណាក៏ដោយតែយើងឃើញថាជីវិតខាងវិញ្ញាណ ឬគំរូតាមជំនឿតាមពួកគាត់ក៏អាចអនុវត្តន៍បាននៅក្នុងសង្គមសព្វថ្ងៃនេះរបស់យើងផងដែរ។ ពួកគាត់ជាគំរូសម្រាប់យើងសូម្បីតែបងប្រុសបងស្រីដែរមានឈ្មោះនៅទីនោះសុទ្ធតែអ្នកបម្រើព្រះសហគមន៍មែនទែនជាពិសេសខាងអប់រំជំនឿ ខាងមើលក្មេងពិការ ឬក៏ក្មេងកំព្រា ដូច្នេះហើយជីវិតរបស់ពួកគេហាក់ដូចជាមិនឆ្ងាយពីយើងទេ ប៉ុន្តែគាត់ខិតខំមែនទែនដើម្បីឲ្យរក្សាទុកនូវជំនឿក្នុងស្ថានការណ៍ដែលពិបាកនៅពេលនោះ ដូចជាការស្រឡាញ់របស់ពួកយើង សព្វថ្ងៃនេះយើងអាចចាត់ទុកថាជាការពិបាកដែរ សូមឲ្យមរណសាក្សីទាំងនោះជួយអធិដ្ឋានសម្រាប់យើងផង ៕



# មេដឹកនាំអាស៊ានគឺភាគច្រើនមានអាយុពីជាង ៦០ ទៅជាង ៧០ឆ្នាំ




សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថាអាស៊ានជាអង្គការថ្នាក់តំបន់មួយរួមមានប្រទេសនៅអាស៊ីអគ្នេយ៍ទាំងដប់ ហើយ ដែលឥឡូវនេះ បានរួមរួមគ្នាបង្កើតជាសហគមន៍អាស៊ាន គឺកំពុងតែ ដឹកនាំដោយ មេដឹកនាំ ដែលពោរពេញទៅដល់សក្តានុពល និងបទពិសោធន៍។

តាមការស្រាវជ្រាវអំពីប្រវត្តនៃមេដឹកនាំអាស៊ានទាំង១០ ប្រទេស បានបង្ហាញថា ភាគច្រើននៃមេដឹកនាំ បណ្តាប្រទេសនៅក្នុងសហគមន៍អាស៊ានទាំងអស់ គឺមានអាយុ ចន្លោះពី ៦០ទៅ ៧០ឆ្នាំ ជាង ដែលនេះ គឺជាចន្លោះអាយុមួយ ដែលពោរពេញទៅដោយបទពិសោធន៍ និងសក្តានុពលនៅក្នុងការងារនយោបាយ និងដឹកនាំប្រទេស។

នៅក្នុងចំណោមមេដឹកនាំអាស៊ានទាំង ១០ ប្រទេសយើងឃើញថា ប្រទេសខ្លះ គឺមានមេដឹកនាំដែលមាន អាយុរហូតដល់ទៅជិត ១០០ឆ្នាំ ហើយមេដឹកនាំដែលក្មេងជាងគេនោះ គឺមិនក្រោម៥០ឆ្នាំឡើយ។

តាមការសិក្សាស្រាវជ្រាវ យើងខ្ញុំដឹងថា នៅក្នុងប្រទេសសមាជិកសហគមន៍អាស៊ានទាំង ១០ ម៉ាឡេស៊ី មានមេដឹកនាំចាស់ជាងគេ បន្ទាប់មកប្រទេសឡាវ ប្រទេសវៀតណាម ប្រទេសហ្វីលីពិន ប្រទេសភូមា ប្រទេសប្រុយណេ ប្រទេសសិង្ហបុរី ប្រទេសកម្ពុជា ប្រទេសថៃ និងប្រទេសឥណ្ឌូនេស៊ី។

នៅក្នុងចំណោមប្រទេសទាំងនោះគេបានដឹងថា សម្រាប់ប្រទេសម៉ាឡេស៊ី ដែលកំពុងតែដឹកនាំដោយ លោក មហាធៀប៊ិន មូហាមាត់ ត្រូវបានគេដឹងថា គឺជាមេដឹកនាំដែលមានអាយុ ៩៣ឆ្នាំ។ លោកបានធ្លាប់ ដឹកនាំ ប្រទេសម៉ាឡេស៊ីនៅក្នុងនាមជានាយករដ្ឋមន្ត្រីតាំងពីឆ្នាំ១៩៨១ ដល់ឆ្នាំ២០០៣ហើយទើបតែឡើងកាន់អំណាចវិញនាពេលថ្មីៗនេះ។ នៅក្នុងចំណោមមេដឹកនាំអាស៊ាន លោកត្រូវបានគេចាត់ទុកថា គឺជាអ្នកដែលចាស់ទុំជាងគេបំផុតនៅពេលនេះទាំងបទពិសោធន៍ទាំងចំណេះដឹង។

បន្ទាប់មក គឺលោក ប៊ូញ៉ាង វ៉ូរ៉ាជិត ដែលគេដឹងថា គឺជាប្រធានាធិបតីនៃប្រទេសឡាវ។ លោកមិនមែនជា អ្នកដឹកនាំឡាវដោយផ្ទាល់ដើម្បីបង្ហាញមុខនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាននោះទេ ប៉ុន្តែគឺជាជនទីមួយនៅក្នុងអំណាចនៅក្នុងប្រទេសដែលមានព្រំដែនជាដីគោកមួយនេះ។ មកដល់ពេលនេះលោក ត្រូវបានគេដឹងថា គឺជាមេដឹកនាំដែលមានវ័យ ៨១ឆ្នាំ។ លោកត្រូវបានគេដឹងថា គឺជាអ្នកនយោបាយ និងជាមេដឹកនាំចាស់ទុំមួយរូបនៅអាស៊ាននេះផងដែរ ថ្វីត្បិតតែកិត្តិនាមរបស់លោកនៅក្នុងអាស៊ានមិនសូវល្បីល្បាញក៏ដោយ។

លោក ង្វៀន ភូ ទ្រុង ដែលគេដឹងថា គឺជាអគ្គលេខាធិការនៃគណបក្សកុម្មុយនីស្តវៀតណាម។ មកដល់បច្ចុប្បន្ននេះ លោកមានអាយុប្រមាណជា ៧៤ឆ្នាំ។ លោកក៏ជាមេដឹកនាំប្រទេសអាស៊ានមួយ ដែលមិនបានចុះជាប់ និងកាន់កាប់ការងារអាស៊ាននេះដោយផ្ទាល់នោះទេ ដោយអ្នកដែលកាន់កិច្ចការអាស៊ាន គឺជានាយករដ្ឋមន្ត្រី ដែលស្ថិតនៅក្រោមការជ្រើសរសើពីគណបក្ស។ នៅក្នុងប្រទេសវៀតណាម គឺមានប្រធានាធិបតី និងនាយករដ្ឋមន្ត្រី ប៉ុន្តែនៅក្នុងតំណែងជាអគ្គលេខាធិការគណបក្សកុម្មុ-នីស្តនេះ គឺលោកទ្រុងត្រូវបានគេអះអាងថា គឺជាជនកំពូលនៅក្នុងប្រទេសនេះតែ ម្តង។

នៅក្នុងបញ្ជីមេដឹកនាំអាស៊ាន លោក រ៉ូឌ្រីហ្គោ ឌូទែតេ ក៏ជាមេដឹកនាំអាស៊ានមានវ័យ ៧៣ឆ្នាំមួយរូបផងដែរ។ នៅក្នុងតំណែងជាប្រធានាធិបតី ហ្វីលីពិន លោក កំពុងតែកាន់កាប់កិច្ចការនេះដោយផ្ទាល់ ហើយកំពុងតែប្រឡូកនៅក្នុងកិច្ចការនេះ ជាបន្តបន្ទាប់ ដោយលោក ក៏បានរៀបចំកិច្ចប្រជុំកំពូលអាស៊ាន កាលពីឆ្នាំទៅផងដែរ។

លោកស្រី អ៊ុង សាន សូជី ដែលគេដឹងថា មិនមែនជា ប្រធានាធិបតី ឬជានាយក-រដ្ឋមន្ត្រី ភូមា ប៉ុន្តែនៅក្នុងតំណែងមួយដែលលោកស្រីបានបង្កើតខ្លួនឯង ក្រោយពីដឹកនាំគណបក្សលោកស្រី ឈ្នះការបោះឆ្នោត លោកស្រី អាចជាស្ត្រីមេដឹកនាំអាស៊ានមួយរូប ដែលមានបទពិសោធន៍មួយរូបផងដែរ។ នៅក្នុងវ័យ ស្របាលគ្នានឹង លោកប្រធានា-ធិបតីហ្វីលីពិន លោកស្រីក៏មានវ័យ ៧៣ឆ្នាំផងដែរ។ លោកស្រី អាចចាត់ទុក ជាជនខ្លាំង និងមានបទពិសោធន៍ខាងនយោបាយមួយរូប បើទោះបីជាពេលនេះ លោកស្រីកំពុង តែដឹកនាំប្រទេសភូមា ឆ្លងកាត់ព្យុះនយោបាយអន្តរជាតិដ៏គ្រោតគ្រាត រឿងជនជាតិមូស្លីមរ៉ូហ៊ីងយ៉ា ដែលវិបត្តិនេះនៅមិនទាន់មានដំណោះស្រាយនៅឡើយក៏ដោយ។ លោកស្រីត្រូវបានគេដឹងថា បានបង្ហាញមុខនៅក្នុងកិច្ចប្រជុំកំពូល អាស៊ានជាបន្តបន្ទាប់ ជួនកាលកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានផងដែរ។

ព្រះចៅស៊ុលតង់ ហាសាណាល ប៊ូលគៀរ គឺជាជនលេចធ្លោរមួយរូបនៅអាស៊ាន ដោយសារតែ ព្រះអង្គ គឺលេចមុខនៅកិច្ចប្រជុំកំពូលអាស៊ានរាល់ឆ្នាំ។ ព្រះអង្គគឺជាអង្គព្រះមហាក្សត្រតែមួយគត់ ដែលមាន មុខនៅពេលកិច្ចប្រជុំកំពូលអាស៊ាន។ ព្រះអង្គត្រូវបានគេដឹងថា មានព្រះជន្ម ៧២ឆ្នាំ។

លោក លី ស៊ានឡុង នាយករដ្ឋមន្ត្រីនៃប្រទេសសិង្ហបុរី ត្រូវបានគេដឹងថា គឺជារដ្ឋបុរសកំពូលមួយរូប នៅក្នុងចំណោមបណ្តាឥស្សរជនអាស៊ានទាំង១០។ នៅក្នុងឆ្នាំនេះ លោកកំពុងតែកាន់តំណែងជាប្រធានអាស៊ាន។ លោក ត្រូវបានគេដឹងថា មានអាយុ ៦៦ ឆ្នាំ ។

សម្តេចតេជោ ហ៊ុន សែន គឺជារដ្ឋបុរសកំពូលមួយនៅអាស៊ាន។ សម្តេចតេជោមានអាយុ៦៦ ឆ្នាំ ហើយ បានប្រកាសថានឹងបន្តដឹកនាំប្រទេសបន្តទៀត រហូតដល់ ១០ឆ្នាំទៀតប្រសិនបើប្រជាពលរដ្ឋបន្តគាំទ្របន្តទៀត ។

លោក ប្រាយុទ្ធ ចាន់អូ៊ចារ គឺជានាយក-រដ្ឋមន្ត្រី ដែលឡើងកាន់អំណាចនៅក្នុងប្រទេសថៃនៅពេលបច្ចុប្បន្ន តាមការធ្វើរដ្ឋប្រហារ គឺត្រូវបានគេដឹងថា គឺមានអាយុ ៦៤ឆ្នាំ។ ហើយមេដឹកនាំដែលក្មេងជាងគេ នៅអាស៊ាននោះ ត្រូវបានគេដឹងថា គឺលោក ជូកូ វីដូដូ ប្រធានាធិបតីឥណ្ឌូនេស៊ី។ លោកត្រូវបានគេដឹងថា គឺមានអាយុ ទើបតែ ៥៧ ឆ្នាំ តែប៉ុណ្ណោះ ៕

*ដោយ អរិយបុត្រ*

# អាជ្ញាធរកម្ពុជាបានដោះលែង អ្នកនយោបាយ អ្នកវិភាគ សកម្មជនដីធ្លី និងអ្នកសារព័ត៌មាន២០រូប

អ្នកនយោបាយនិងសកម្មជន សកម្មជនដីធ្លី អតីតបុគ្គលិកវិទ្យុអាស៊ីសេរី និងអ្នកវិភាគនយោបាយ ត្រូវបានតុលាកាដោះលែងឲ្យមានសេរីភាពវិញជាបន្តបន្ទាប់ ចាប់តាំងពីថ្ងៃទី១៧ ដល់ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ គឺមានចំនួនជាង២០នាក់ ដោយភាគច្រើនគឺទទួលបានការលើកលែងទោសពីព្រះមហាក្សត្រតាមការទូលស្នើសុំពីសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។

អ្នកទាំងនោះ មានដូចជា លោក គឹម សុខ អ្នកវិភាគនយោបាយ និងសង្គមត្រូវបានតុលាការដោះលែង កាលពីវេលាម៉ោងប្រមាណ៩ និង៣០នាទី ព្រឹកថ្ងៃទី១៧ សីហា ២០១៨ ក្រោយអនុវត្តការជាប់ទោសដល់ថ្ងៃកំណត់។ លោក គឹម សុខ ត្រូវបានឃុំខ្លួនកាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ ពាក់ព័ន្ធនឹងការលើកឡើងរបស់លោកតាមរយៈវិទ្យុអាស៊ីសេរីថា គណបក្សប្រជាជននៅពីក្រោយការសម្លាប់លោក កែម ឡី ដែលត្រូវខ្មាន់កាំភ្លើងបាញ់សម្លាប់កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៦។

លោកស្រី ទេព វន្នី និងសកម្មជនដីធ្លីចំនួន៣នាក់ទៀត គឺ អ្នកស្រី ហេង មុំ លោកស្រី បូ ឆវី និងអ្នកស្រីគង់ ចន្ថា ត្រូវបានដោះលែងពីពន្ធនាគារព្រៃសវេលាម៉ោង ប្រមាណ ៨ និង៤០នាទីយប់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ ក្រោយពេល តុលាការរាជធានី ភ្នំពេញ បានសម្រេចផ្តន្ទាទោសពួកគេ កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៧ ។

អតីតបុគ្គលិកវិទ្យុអាស៊ីសេរី ២រូប គឺលោក អ៊ួន ឈិន និងលោក យាង សុជារិន (យាង សុជាមេត្តា) ត្រូវបានដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន នាល្ងាចថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ក្រោយពី ត្រូវបានតុលាការឃុំខ្លួនអស់រយៈពេលជាង ៨ខែមកហើយ ក្រោមបទចោទ "ផ្តល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ដែលនាំឱ្យអន្តរាយដល់ការការពារជាតិ"។

លោក សួន សេរីរដ្ឋា អតីតប្រធានគណបក្សអំណាចខ្មែរ ត្រូវបានដោះលែង កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ ក្រោយពីត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៧ ក្រោយពីត្រូវកាត់ទោស ពីបទញុះញង់កុំឱ្យយោធិនស្តាប់បង្គាប់, ធ្វើឱ្យខូចទឹកចិត្តកងទ័ព និង ញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ ។

លោកអ៊ុំ សំអាន អតីតតំណាងរាស្ត្រមណ្ឌលខេត្តសៀមរាបរបស់អតីតគណបក្សសង្គ្រោះជាតិ ត្រូវបានដោះលែងឲ្យមានសេរីភាពវិញហើយ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨ ក្រោយការចាប់ខ្លួនកាលពីថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១៦ នៅក្នុងខេត្តសៀមរាប បន្ទាប់ពីលោកត្រឡប់ពីសហរដ្ឋអាមេរិក។

ក្រៅពីនោះ លោក មាជ សុវណ្ណារ៉ា អតីតមន្ត្រីជាន់ខ្ពស់ និងសកម្មជនអតីតគណបក្សសង្គ្រោះជាតិ លោកយិន រឿន ហៅ យិន ជំរឿន លោកអឿ ណារិទ្ធ លោកនាង សុឃុន លោកសាន គីមហេង លោកសាន សីហៈ លោកអ៊ុក ពេជ្រសំណាង លោកទេព ណារិន លោកអាន បឋម លោកកែ ឃីម លោកស៊ុំ ពុទ្ធិ លោករឿន ចិត្រា លោកយន់ គឹមហួរ និងលោកយា ដុង ដែលសុទ្ធតែជាសកម្មជន និងអ្នកគាំទ្រអតីតគណបក្សប្រឆាំងមួយនេះ ក៏ត្រូវបានលើកលែងទោស និងដោះលែងផងដែរ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨៕

# ក្រសួងកសិកម្មកំពុងអនុវត្តគម្រោងជំរុញផលិតកម្មស្បៀងនឹងបង្កើនការដាំដុះបន្លែក្នុងស្រុក

កម្ពុជាកំពុងតែអនុវត្តគម្រោងផលិតកម្មស្បៀងឆ្នាំ ២០១៦-ឆ្នាំ២០១៩ ហើយកំពុងតែជំរុញការដាំដុះដំណាំក្នុងស្រុកនៅខេត្តចំនួនមួយចំនួន ដើម្បីជំនួសការនាំចូលបន្លែពីប្រទេសជិតខាង។

ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានថ្លែងថា គម្រោងផលិតកម្មស្បៀងបានដាក់ឲ្យដំណើរកាលពីឆ្នាំ២០១៧ ហើយនៅឆ្នាំ ២០១៨នេះ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ កំពុងតែអនុវត្តយ៉ាងពេញតែម្តងដែលក្រសួងបានរៀបចំពិព័រណ៍ផ្សារណាត់បន្លែនៅតាមបណ្តាខេត្តជាគោលដៅទាំង១៣ ដើម្បីបង្ហាញឲ្យឃើញរវាងអ្នកទិញនិងអ្នកផលិតបានធ្វើទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធជៀងរវាងការផលិតលើសតម្រូវការទីផ្សារ។

ឯកឧត្តម បានបន្តទៀតថា ចំពោះពិព័រណ៍ផ្សារណាត់នេះបានធ្វើនៅខេត្តចំនួន៣រួចមកហើយ គឺនៅកំពង់ចាម កណ្តាល និងខេត្តព្រៃវែង ហើយនៅពេលខាងមុខនេះគ្រោងនឹងរៀបចំបន្តទៀតនៅបាត់ដំបង ពោធិសាត់ សៀមរាប និងខេត្តកំពង់ធំ ដើម្បីបើកចំហរដល់ប្រជាពលរដ្ឋនៅតាមផ្សារ និងអ្នកបញ្ជាទិញបានដឹងពីតម្រូវការទីផ្សារជាក់ស្តែងតែម្តង។

ចំណែក លោក ចាន់ សុផល នាយកមជ្ឈមណ្ឌលសិក្សាគោលនយោបាយ(CPS) បានថ្លែងថា គម្រោងនេះ ដើម្បីបំពេញតាមសភាពការណ៍ជាក់ស្តែងនៅទីក្រុងភ្នំពេញ ដែលគម្រោងកន្លងមកច្រើនធ្វើតាមជនបទមានលក្ខណៈតូចតាច ហើយមិនទាន់បានឆ្លើយតបការចង់បានរបស់ប្រជាពលរដ្ឋនៅឡើយ។

រដ្ឋាភិបាលកម្ពុជា តាមរយៈអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានប្រើប្រាស់ថវិកាចំនួន ២០លានដុល្លារក្នុង គម្រោងកម្មវិធីជម្រុញផលិតកម្មស្បៀង នៅក្នុងដំណាក់កាលទី១ ឆ្នាំ ២០១៦-២០១៨។

កម្មវិធីនេះនឹងជំរុញផលិតកម្មស្រូវក្រអូប និងបន្លែមួយចំនួនជំនួសឲ្យការនាំចូលតាមរយៈការជម្រុញការផលិតពូជស្រូវក្រអូបបន្ថែមទៀតឲ្យបាន ១៥០០០ តោនក្នុង ១ឆ្នាំ នឹងបង្កើនការដាំដុះបន្លែបន្ថែមឲ្យបានចំនួន ៧០០០០ តោនក្នុង១ឆ្នាំ នៅឆ្នាំ២០១៨ខាងមុខនេះ៕

# ចំនួនប្រជាជនពិភពលោកនឹងឈានដល់៩,៩ ពាន់លាននៅត្រឹមឆ្នាំ២០៥០

ការប៉ាន់ស្មានដោយការិយាល័យប្រជាពលរដ្ឋ (PRB) បានឲ្យដឹងថា ចំនួនប្រជាជនពិភពលោក នឹងកើនឡើងដល់ ៩,៩ ពាន់លាននាក់ត្រឹមឆ្នាំ ២០៥០ ពោលគឺកើនឡើង២,៣ ពាន់លាននាក់ ឬ២៩ភាគរយ ពីប្រជាជនប្រមាណ ៧,៦ ពាន់លាននាក់ដែលមាននៅក្នុងពេលបច្ចុប្បន្ន។

ប្រភពដដែល បាននិយាយថា ការចេញផ្សាយការព្យាករណ៍ឆ្នាំនេះ បានផ្តល់នូវទិន្នន័យថ្មីៗបំផុតស្តីពីសូចនាករប្រជាជន, សុខភាព និងបរិស្ថានសំខាន់ៗចំនួន២៦ សម្រាប់ពិភពលោក, តំបន់នៅលើពិភពលោក ប្រទេស និងដែនដីជាង២០០ ដោយរួមបញ្ចូលទាំងប្រទេសកម្ពុជាផងដែរ។

យោងតាមការព្យាករណ៍ប្រទេសឥណ្ឌានឹងក្លាយជាប្រទេសមានប្រជាជនច្រើនបំផុតលើពិភពលោកដែលមានប្រជាជន១.៦៨០ លាននាក់ បន្ទាប់មកប្រទេសចិនមានចំនួន១.៣៤០ លាននាក់ នីហ្សេរីយ៉ាចំនួន ៤១១ លាននាក់ សហរដ្ឋអាមេរិកមានចំនួន៣៩០ លាននាក់ និងឥណ្ឌូនេស៊ីចំនួន៣២០ លាននាក់។

ចំនួនប្រជាជននៃប្រទេសចំនួន២៦ ស្ទើរតែទាំងអស់នៅអាហ្វ្រិកនឹងកើនឡើងយ៉ាងហោចណាស់ពីរដង។ ប្រទេសនីហ្សេរីនៅអាហ្វ្រិកខាងលិចនឹងឃើញប្រជាជនរបស់ខ្លួនជិតបីដង។ ប្រទេសចំនួន៣៨ នឹងមានចំនួនប្រជាជនតិចជាងឆ្នាំ២០១៨ នាឆ្នាំ២០៥០ខាងមុខ។ ប្រទេសចិននឹងចុះបញ្ជីពីការថយចុះចំនួនប្រជាជនដែលមានចំនួនប្រជាជនច្រើនជាងគេនៅពេលបច្ចុប្បន្ន គឺប្រហែល៥០ លាននាក់បន្ទាប់មកប្រទេសជប៉ុនមានចំនួន ២៥ លាននាក់ និងរុស្ស៊ីមានចំនួន៩,៤ លាននាក់។

ប្រទេសរ៉ូម៉ានីនឹងមើលឃើញពីការថយចុះភាគរយនៃប្រជាជនភាគច្រើន ២៣ ភាគរយ ។

ប្រទេសជាច្រើនក្នុងពិភពលោកកំពុងជួបប្រទះហើយនឹងបន្តជួបប្រទះភាពចាស់ជរានៃប្រជាជនដោយមានការកើនឡើងជាលំដាប់នូវចំនួននៃមនុស្សចាស់ៗទាំងក្នុងន័យដាច់ខាតនិងជាភាគរយនៃចំនួនប្រជាជនសរុប។ និន្នាការនេះបង្កឱ្យមានបញ្ហាប្រឈមសម្រាប់ប្រទេសនានាក្នុងការធ្វើឱ្យមានតុល្យភាពរវាងប្រាក់សោធននិវត្តន៍ សុខភាព និងអត្ថប្រយោជន៍ដទៃទៀតដែលមនុស្សចាស់ទទួលបានក្នុងការវិនិយោគទៅលើសុខុមាលភាពរបស់មនុស្សជំនាន់ក្រោយ៕

# កម្ពុជាឥឡូវបានសុខហើយ មិនចង់ឃើញទិដ្ឋភាពអ្វីកើត

ប្រជាពលរដ្ឋកម្ពុជា ដែលមានវ័យប្រហាក់ប្រហែលជា ៥០ឆ្នាំជាង មួយចំនួនបានថ្លែងអះអាងថា កម្ពុជានៅពេលនេះបានសុខហើយ បើទោះបីជាវាមិនដូចជាប្រទេសគេក៏ពិតមែន ប៉ុន្តែក៏ប្រហាក់ប្រហែលនឹងគេខ្លះដែរ ។

លោក ទៀ សុវណ្ណ ជាអ្នកដំណើរដែលកំពុងតែនាំគ្រួសារឈប់សម្រាកលំហែលេងនៅតាមផ្លូវ ៦០ ម៉ែត្រ ភាគខាងត្បូងនៃរាជធានីភ្នំពេញ បានឲ្យដឹងថា កម្ពុជានាពេលបច្ចុប្បន្ននេះ បើទោះបីជាមិនដល់ប្រទេសជិតខាង ប៉ុន្តែយ៉ាងហោចណាស់គេមានអី យើងក៏មាននោះនឹងគេដែរ ។

ដោយឈរសម្លឹងរាជធានីភ្នំពេញពីភាគខាងត្បូង តាមទិសទៅខាងជើងវិញ ទិដ្ឋភាពទីក្រុង និងសកម្មភាពទីក្រុង គឺមើលទៅមិនខុសពីទិដ្ឋភាពនៅទីក្រុងនៅប្រទេសគេប៉ុន្មានឡើយ។ សំណង់ និងអាគារខ្ពស់ៗបានប្រាកដឡើងនៅចំពោះមុខអ្នកដំណើរគ្រប់គ្នា នោះលោក សុវណ្ណ បានបន្តទៀតថា មើលទៅទីក្រុងយើងទៅដឹងហើយពីមុនមានស្អី ប៉ុន្តែឥឡូវនេះមានស្អី ។

លោកបានបន្តទៀតថា ឲ្យតែលោកបានធ្វើដំណើរឆ្លងកាត់ផ្លូវនេះ លោកតែងតែឈប់ និងដើរគយគន់មើលទិដ្ឋភាពរាជធានីភ្នំ-ពេញជានិច្ច ដោយសារតែវាមើលទៅស្អាតហើយ បញ្ជាក់អំពីការ រីកចម្រើននៃទីក្រុង និងប្រទេស។ លោក បានថ្លែងបន្តទៀតថា នេះពេលថ្ងៃទេ តែបើបានឆ្លងកាត់ពេលមេឃអត់ពន្លឺព្រះអាទិត្យ យើងនឹងឃើញទិដ្ឋភាពដ៏អស្ចារ្យប្រាកដខ្លួនឡើង នៅចំពោះយើង ហើយ បើមិនដែលបានដឹង គឺពិតជាភ្ញាក់ផ្អើលមែនទែន នឹងទិដ្ឋភាពនេះ។

លោកបានបញ្ជាក់ថា "នេះគឺជាសមិទ្ធផលនៃសន្តិភាព បើគ្មានសន្តិភាព នោះប្រហែលជាយើងមិនអាច ឃើញទិដ្ឋភាពទាំងនេះបានទេ"។

លោកបានបន្តទៀតថា ទិដ្ឋភាពបែបនេះប្រហែលជាមិនអាចរកឃើញនៅកម្ពុជា នៅក្នុងអំឡុងនៃទសវត្សរ៍នៃឆ្នាំ១៩៧០-១៩៨០នោះបានទេ ដោយសារតែពេលនោះ ស្រុកយើង គឺកំពុងតែហ៊ឹករ មែនទែន ទូទាំងប្រទេសគឺឮតែស្នូកាំភ្លើង ។

លោកបានបន្តទៀតថា ឥឡូវនេះមិនមែនមិនឮស្នូកាំភ្លើងទេ គឺឮមួយៗដែរ ប៉ុន្តែគឺជាស្នូ កាំភ្លើងចោរប្លន់ម្តងម្កាល ជនពាលាអាវ៉ាសែរ ផឹកស្រវឹងបាញ់បោះ តែប៉ុណ្ណោះ រីឯស្នូ គ្រាប់បែក កាំភ្លើង ផ្លោង គ្រាប់មីន អីលែងមានហើយ ទីក្រុង ទីប្រជុំជននីមួយៗ ឮតែ សម្លេង រថយន្ត ម៉ូតូ ធុញនឹងការកកស្ទះចរាចរណ៍ទៅវិញ ។



លោកបានបញ្ជាក់ទៀតថា "ស្រុកយើងឥឡូវនេះ ដើរដល់ប៉ុណ្ណឹងហើយចង់ទៅរកអីទៀត"។

លោក សម ថារិន ជាប្រជាពលរដ្ឋវ័យកណ្តាលមួយរូប បានអះអាងពីមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ភ្នំតាម៉ៅ ថា ស្រុកយើងប៉ុណ្ណេះហើយ ចង់ទៅរកទីទៀត។ លោកបានបន្តទៀតថា ឥឡូវចុងសប្តាហ៍ អ្នកខ្លះមិនសូវនៅផ្ទះទេ បើកឡានដើរលេងបាត់ មិនដូចសម័យមុន (ទសវត្សរ៍ ពីឆ្នាំ ១៩៧០-១៩៨០ ) ម្នាក់ៗនៅតែផ្ទះ ទេ

## តើអ្វីទៅជាប្រព័ន្ធ "អ្វីៗគ្រប់យ៉ាងលើលែងតែអាវុធ?" តើវាសំខាន់យ៉ាងណាសម្រាប់កម្ពុជា?

យោងទៅតាមក្រសួងពាណិជ្ជកម្ម "អ្វីៗគ្រប់យ៉ាងលើលែងតែអាវុធ" ត្រូវបានអនុម័តដោយ វិធានរបស់ក្រុមប្រឹក្សាសហភាពអឺរ៉ុប លេខ No.416/2001 ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០១។ វា គឺជាគំនិតផ្តួចផ្តើម របស់សហភាពអឺរ៉ុប ដែលអនុញ្ញាតឱ្យ ការនាំចូលទំនិញទាំងអស់ លើកលែងតែសព្វាវុធ ទៅសហភាពអឺរ៉ុបពីប្រទេសអភិវឌ្ឍន៍តិចតួចទទួលនូវការអនុគ្រោះដោយមិនជាប់ពន្ធនាំចូលនិងកូតា។ វាគឺជាផ្នែកនៃប្រព័ន្ធអនុគ្រោះទូទៅរបស់សហភាពអឺរ៉ុប ដែលបានចូលជាធរមានចាប់តាំងពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០១មកម្លេះ និងគ្មានកំណត់ពេលវេលាបញ្ចប់នោះទេ។ ទំនិញនាំចូលទាំងអស់នឹងត្រូវទទួលបាននូវការអនុគ្រោះមិនជាប់ពន្ធនាំចូល និងកូតា ប្រសិនបើអនុលោមទៅតាមវិធានប្រភពដើមទំនិញ និងបណ្តាវិធានពាក់ព័ន្ធដទៃទៀត។

គម្រោងនេះគ្រប់ដណ្តប់ទៅលើផលិតផលប្រមាណ៧.២០០បន្ទាត់ពន្ធគយ ក្នុងនោះ៩១៩បន្ទាត់ពន្ធគយ គឺជាផលិតផលកសិកម្ម។ ប្រទេសអភិវឌ្ឍន៍តិចតួចចំនួន៤៨ រួមទាំងកម្ពុជាផងដែរ ទទួលបានការអនុគ្រោះពីគំនិតផ្តួចផ្តើមនេះ។

ចំពោះកម្ពុជាវា ផ្តល់ផលប្រយោជន៍យ៉ាងខ្លាំងដល់វិស័យកសិកម្ម ជាពិសេស អង្ករ និងផលិតផលសក្តានុពលមួយចំនួនទៀត។ ជាក់ស្តែង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានបង្កើនការនាំចេញអង្ករយ៉ាងច្រើនទៅសហភាពអឺរ៉ុប ជាពិសេសប្រទេសបារាំង អ៊ីតាលី ជាដើម។ ដូចគ្នាដែរ ការនាំចេញ សំលៀកបំពាក់ទៅសហភាពអឺរ៉ុបក៏កើនឡើងគួរឱ្យកត់សម្គាល់ដែរ។ ការនាំចេញអាចប្រព្រឹត្តទៅ បាន ដោយសារតែការបន្ធូរបន្ថយលើវិធានប្រភពដើមទំនិញដែលកំណត់ធាតុផ្សំក្នុងស្រុក (local content) ត្រឹមតែ៣០ភាគរយប៉ុណ្ណោះ៕

# តឡើងកាលពីទស្សវត្សរ៍នៃឆ្នាំ១៩៧០-១៩៨០ នោះទេ


ថតដោយ: អាន វិទ្ធីរដ្ឋ

ដោយសារតែលុយក៏វាអត់ ផ្លូវក៏វាលំបាក ហើយវាគ្មានស្ពានដិះ ហើយវាអសន្តិសុខទៀត ដោយសារតែប្រទេសមិនសូវមានសន្តិភាព។ លោកបានបន្តទៀតថា កាលអំឡុងពេលនោះ ចង់ប្រមូលគ្នីគ្នា បានដើរលេង ត្រឹមទន្លេបាទី ត្រឹមឧត្តុង្គអី សន្សំលុយរាប់ខែ ហើយបានមកម្តងៗ វេចបាយ ខ្ចប់ម្ហូប ហើយនាំគ្នា ស្មើឡានស្លាប៍នមន្ទីររដ្ឋអីនោះបានមកបាន មិនដូចសម័យនេះនឹងឃើញភ្លែតមកប្រុយនោះទេ។

ដោយមានវ័យត្រឹមតែ ៤៥ ឆ្នាំ លោក ថារិន បានចូលរួមរំលឹកនូវការចងចាំរបស់លោក មួយចំនួន កាលពីអំឡុងទស្សវត្សរ៍មុនៗថា វាមិនអាចចងចាំអស់នូវរឿងរ៉ាវអតីតកាលបានទេ ហើយលោក ក៏មិនបានចងចាំនៅរឿងរ៉ាវ ទស្សវត្សរ៍នៃឆ្នាំ១៩៧០ នោះដែរ ដោយអះអាងថា លោកកើតទាន់ខ្លះ តែមិនចាំទេ អ្វីដែលចាំបានគឺ នៅក្នុងអំឡុងទស្សវត្សរ៍ នៃឆ្នាំ១៩៨០។

លោកបានបន្តទៀតថា រឿងរ៉ាវ ដែលកើតមានអំឡុងឆ្នាំ១៩៧០ គឺពិបាកចាំ ដោយសារតែអាយុវាតិច តែចាំខ្លះៗនៅសម័យ ប៉ុលពត តែមិនច្រើនទេ ហើយនៅចងចាំបានច្បាស់ គឺនៅក្នុងអំឡុងទស្សវត្សរ៍ នៃឆ្នាំ១៩៨០មក។

លោកបានបន្តទៀតថា សម័យនោះ វាមិនមែនបានន័យថា នៅកម្ពុជាមានសង្គ្រាមគ្រប់កន្លែងនោះទេ ហើយប្រជាពលរដ្ឋគ្មានសិទ្ធិធ្វើដំណើរទៅណាមកណា នោះទេ គ្រាន់តែថា វាគ្មានមធ្យោបាយ។ សម័យនោះ ភាគច្រើនរស់នៅណា ដើរលេងរីករាយអី តែក្រវិលៗកន្លែងនោះ ដោយសារវាអត់ផ្លូវ បើមានផ្លូវ ផ្លូវវាលំបាក អត់មានស្ពានដិះ ។ យើងចង់ទៅលេងត្រឹម តែខេត្តតាកែវអី ទាល់តែ ដេកមួយ យប់ពីរឡើង បានទៅ ។ លោកបានបន្តទៀតថា សម័យនោះ អ្នកនៅភ្នំពេញ គឺអាចដើរលេងបាន ត្រឹមតែទន្លេបាទី បើចង់ទៅដល់ភ្នំជីសូ ក៏ចង់យ៉ាប់ដែរ។ បើបើចង់ទៅតាមផ្លូវជាតិលេខ ៤វិញ អស់ហើយត្រឹមពពែភ្នំ ហើយ បើនៅផ្លូវជាតិលេខ ៥ គឺត្រឹមភ្នំប្រសិទ្ធិ និងភ្នំឧត្តុង្គ គឺអស់ហើយ ផ្លូវជាតិលេខ១វិញ ច្រើនត្រឹមគៀនស្វាយ។

លោក ថារិន បានបញ្ជាក់ថា "ឥឡូវឲ្យតែចង់ និងមានកម្លាំង មានលុយ ចង់ទៅដល់រតនគិរី ចម្ងាយជាង ៥០០គម វិលល្ងាចក៏បានដែរ"។

បុរសម្នាក់ដែលមានវ័យ៣៩ ឆ្នាំ ប៉ុន្តែសុំមិនបញ្ចេញអត្តសញ្ញាណដោយប្រាប់ថា គឺជាមន្ត្រីរាជការមួយរូប បានចូលរួមបញ្ចេញយោបល់ថា កម្ពុជានៅពេលនេះ គឺពិតជាមានការអភិវឌ្ឍន៍ មានសន្តិភាព មានទីផ្សារច្រើន ប៉ុន្តែក្រៅពីសង្គ្រាមក្តីបារម្ភដែលលោកកំពុងតែមាននោះ គឺថា ប្រទេសអាចនឹងរងនូវទណ្ឌកម្មសេដ្ឋកិច្ចពី អឺរ៉ុប និងអាមេរិក។

លោកបានអះអាងថា សព្វថ្ងៃនេះ យើងមានការអភិវឌ្ឍ មានស្ថេរភាពសេដ្ឋកិច្ច ប្រជាពលរដ្ឋមានការងារធ្វើ គឺដោយសារតែទីផ្សារនៅអឺរ៉ុប និងអាមេរិក តែបើពួកគេដាក់ទណ្ឌកម្ម ដោយមិនបាច់ដាក់អីទេ គឺគ្រាន់តែ បិទទីផ្សារនាំចេញខោអាវ ទីផ្សារកសិកម្ម គឺ សេដ្ឋកិច្ចយើងចប់តែម្តង ។

លោកបានបញ្ជាក់ថា "ខ្ញុំដូចជាមិនបារម្ភរឿងសង្គ្រាមអីទេដោយសារតែពេលនេះ យើងបានបោះឆ្នោតរួចហើយ ប៉ុន្តែគ្រាន់តែ ការបោះឆ្នោតនេះ អត់មានគណបក្សប្រឆាំងចូលរួម បរទេស គេកំពុងតែរិះគន់ "។

លោកបានបញ្ជាក់បន្តទៀតថា "ត្រឹមតែគេរិះគន់ ចេញសេចក្តីថ្លែងការណ៍សំដែងការព្រួយបារម្ភពីសិទ្ធិមនុស្ស អំពីលទ្ធិប្រជាធិបតេយ្យ បង្កកទ្រព្យសម្បត្តិមេដឹកនាំមន្ត្រីយោធា អីមិនអីទេ ខ្លាចតែគេដកអ៊ីប៊ីអេ (EBA) ។

តាមការបញ្ជាក់របស់លោក គឺថា អ៊ីប៊ីអេនេះ គឺមកពីភាសាអង់គ្លេសថា Everything But Arms ដែលមានន័យថាអ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ។ ទីផ្សារយើងសព្វថ្ងៃនេះ គឺពឹងផ្អែក លើវាជាច្រើន។ លោកមិនបានដឹងលំអិតទេ ប៉ុន្តែលោកបានបន្តថា តាមការអានព័ត៌មានខ្លះៗ គឺថា អ៊ីប៊ីអេនេះ បើដក គឺថា ទំនិញរបស់យើងដែលនាំចេញទៅអឺរ៉ុប នឹងពិបាកតែម្តង ពីព្រោះទំនិញយើងនាំចេញនឹងត្រូវបងពន្ធ ស្មើគេស្មើឯង ហើយបើបង់ពន្ធដូចគេ តម្លៃរបស់យើងនឹងខ្ពស់ជាងគេ។

លោកបានបន្តទៀតថា អឺរ៉ុបជាទីផ្សារធំរបស់កម្ពុជា នៅពេលបច្ចុប្បន្ននេះគឺដោយសារ អ៊ីប៊ីអេនេះឯងហើយបើគេដកឧស្សាហកម្មកាត់ដេរ និងឧស្សាហកម្មធុនស្រាលមួយចំនួន នឹងជួបពិបាក ពីព្រោះទីផ្សារយើងធំ។

លោកបានបញ្ជាក់ថា អ្នកនយោបាយឈ្លោះគ្នាអ្វីឈ្លោះទៅ ប៉ុន្តែសូមកុំយកអ៊ីប៊ីអេ នេះទៅលេងសើច ពីព្រោះវាមិនបណ្តាលឲ្យស្លាប់អស់លោកទេ ប៉ុន្តែវាគឺជារឿងស្លាប់រស់របស់ជីវិតប្រជាជន ពិសេសកម្មករ រោងចក្រឧស្សាហកម្មកាត់ដេរ ។

ការព្រួយបារម្ភបែបនេះ គឺដោយសារតែអ្នកនយោបាយនិរទេសខ្លួនមួយក្រុមកំពុងតែចលនា នៅបរទេស ដើម្បីឲ្យសហគមន៍អន្តរជាតិដាក់ទណ្ឌកម្មមកលើកម្ពុជា ខណៈដែលពួកគេ ត្រូវបានច្បាប់កាត់ទោសហាមឃាត់ធ្វើនយោបាយ ៥ឆ្នាំ ហើយគណបក្សប្រឆាំង ដែលមានអាសនៈនៅក្នុងសភារបស់ពួកគេត្រូវបានរំលាយចោល៕

ដោយ អរិយបុត្រ

## សមិទ្ធផលគ្រួសពីឆ្នាំ២០១៣ដល់២០១៧

យោងតាមរបាយការណ៍សង្ខេបស្តីពីសមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ វិស័យដែលជាមូលដ្ឋានសេដ្ឋកិច្ចកម្ពុជាអភិវឌ្ឍន៍ជាច្រើន ទាំងវិស័យហេដ្ឋារចនាសម្ព័ន្ធ អប់រំ សុខាភិបាលជាដើម ។

ប្រភពដដែលបានឲ្យដឹងថា បណ្តាញផ្លូវថ្នល់នៅកម្ពុជានៅក្នុងអំឡុងពេលនោះ បានពង្រីករហូតដល់ទៅ ១៦.២៩២ គម ដោយរាប់បញ្ចូលទាំងផ្លូវជាតិ និងផ្លូវខេត្ត ប៉ុន្តែមិនរាប់បញ្ចូលផ្លូវជនបទនៅឡើយទេ។ ការដឹកជញ្ជូនផ្លូវអាកាសវិញនោះត្រូវបានគេដឹងថា ជើងហោះហើរនៅក្នុងស្រុក គឺមានរហូតដល់ទៅ១១.៣២៣ជើង ជើងហោះហើរអន្តរជាតិ ៣៣.៧៣១ជើង និងជើងហោះហើរឆ្លងកាត់គឺមាន ប្រមាណជា៥៩.០៩៨ ជើង។

សម្រាប់វិស័យអប់រំវិញនោះ គេដឹងថា កម្ពុជាមានសិស្សដែលបានចុះឈ្មោះចូលរៀននៅបឋមសិក្សា ២,០២ លាននាក់ នៅអនុវិទ្យាល័យចំនយន ៦០៥.១០០ នាក់ និងវិទ្យាល័យ គឺមាន ៣០៣.៨០០នាក់រៀន បរិញ្ញាបត្ររងមាន ២០.៥០០ នាក់ បរិញ្ញាបត្រមាន ១៦៥.៣០០ នាក់អនុបណ្ឌិតមាន ២០.២០០ នាក់ និង មានកម្រិតបណ្ឌិត ១.២០០ នាក់។ នៅទូទាំងប្រទេសកម្ពុជា មានសាកលវិទ្យាល័យ និងវិទ្យាស្ថាន១២១ កន្លែង វិទ្យាល័យ៦៣៣ កន្លែង អនុវិទ្យាល័យ ១.៨៨៤ កន្លែង បឋមសិក្សាចំនួន ៧.៦២១ កន្លែង និងមតេយ្យសិកសាមាន ៤.៦៣២កន្លែង៕

# សិស្ស ថ្នាក់ទី១២ បច្ចេកទេស នៃវិទ្យាល័យបច្ចេកទេស ឯកជនសន្តហ្វ្រង់ស្វ័ ជាប់១០០%



ថតដោយ: លី សុវណ្ណា

សិស្សវិទ្យាល័យបច្ចេកទេសឯកជនសន្តហ្វ្រង់ស្វ័រ ដែលប្រលងបញ្ចប់ឆ្នាំទី៣ ឬថ្នាក់ទី១២ បច្ចេកទេស បានទទួលលទ្ធផលល្អ គឺជាប់១០០% ក្នុងនោះមានសិស្សចំនួន ពីររូបបានទទួលនិទ្ទេស A។

ក្រសួងអប់រំយុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឲ្យមានវិទ្យាល័យបច្ចេកទេស ដែលសិស្សត្រូវរៀនមុខវិទ្យាចំណេះទូទៅ និងបច្ចេកទេស ដែលខ្លួនចូលចិត្តចាប់ថ្នាក់ទី១០ រហូតដល់ទី១២ហើយសញ្ញាបត្ររបស់គេគឺដូចគ្នាទៅនឹងសញ្ញាបត្រចំណេះទូទៅដែរ។ នៅក្នុងប្រទេសកម្ពុជា មានវិទ្យាល័យបច្ចេកទេសចំនួនប្រាំបីកន្លែង។ កម្មវិធីសិក្សាត្រួតពិនិត្យ និងទទួលស្គាល់ដោយក្រសួងអប់រំយុវជន និងកីឡា។ រាល់វិញ្ញាសារប្រលងថ្នាក់ជាតិ ចេញដោយក្រសួង និងត្រួតពិនិត្យដោយផ្ទាល់ដោយនាយកដ្ឋានតម្រង់ទិសនៃក្រសួងអប់រំ។

វិទ្យាល័យបច្ចេកទេសឯកជនសន្តហ្វ្រង់ស្វ័រ ជាវិទ្យាល័យមួយរបស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដែលបានកសាងឡើងនៅកណ្តាលវាលស្រែ នៃភូមិតាភេប ឃុំអង្គគគី ស្រុកត្រាំកក់ ខេត្តតាកែវ ដែលមានលោកអភិបាលអូលីវីយេជាស្ថាបនិក។

លោកយុន សំអាត នាយកវិទ្យាល័យបច្ចេកទេសឯកជនសន្តហ្វ្រង់ស្វ័របានឲ្យដឹងថា វិទ្យាល័យបច្ចេកទេសបានបង្កើតឡើងក្នុងឆ្នាំ២០១៥ ដោយមានការទទួលស្គាល់ដោយក្រសួងអប់រំយុវជន និងកីឡា។ តាមលោកយុន សំអាត បញ្ជាក់ ថា នៅកម្ពុជា សញ្ញាបត្រ ទុតិយភូមិ (បាក់ឌុប) មានបួនផ្សេងគ្នា គឺ បាក់ឌុប ផ្នែកសង្គម បាក់ឌុប ផ្នែកវិទ្យាសាស្ត្រ បាក់ឌុបបំពេញវិជ្ជា និងបាក់ឌុប បច្ចេកទេស ទាំងបួននេះមានតម្លៃស្មើគ្នា។

លោកសំអាត់បានបញ្ជាក់ថា ការប្រលងរបស់សិស្សថ្នាក់បច្ចេកទេស ប្រព្រឹត្តិទៅរយៈបីថ្ងៃគឺមានប្រលងចំណេះដឹងទូទៅ ទ្រឹស្តីបច្ចេកទេស និងការអនុវត្តន៍ផ្ទាល់។ លោកថា ទាំងនេះជាការកំណត់របស់ក្រសួងអប់រំយុវជន និងកីឡា។

តាមក្រសួងអប់រំយុវជន និងកីឡា នៅទូទាំងប្រទេស មានសាលាបច្ចេកទេសចំនួនប្រាំបី កន្លែង នេះជាលើកទីមួយដែលក្រសួងរៀបចំការប្រលងថ្នាក់ជាតិ លើវិជ្ជាជីវៈសម្រាប់ថ្នាក់ទី១២ បច្ចេកទេស ដែលមានសិស្ស ចូលរួមប្រលងចំនួន ១២៥៨នាក់។

ចំពោះសិស្សវិទ្យាល័យបច្ចេកទេស ឯកជនសន្តហ្វ្រង់ស្វ័រ លោកនាយក យុន សំអាត ថា មានសិស្សថ្នាក់ទី១២ ចំនួន២៨នាក់ ស្រី១២នាក់ដែលត្រូវប្រលង ហើយទទួលបានជោគជ័យទាំងអស់។

លក្ខ័ណជ្រើសរើសសិស្សចូលរៀននៅវិទ្យាល័យនេះ គឺសិស្សទាំងអស់ត្រូវមានសញ្ញាបត្របឋមភូមិ( ឌីប្លូម )។ សិស្សអាចដាក់ពាក្យចូលរៀនបាន ហើយក៏អាចស្នើសុំអាហាររូបករណ៍ ពិសាលាផងដែរ។ សាលាមានកម្មវិធីសិក្សាច្បាស់លាស់ និងមានកន្លែងសម្រាប់សិស្សអនុវត្ត ទាំងផ្នែកកសិកម្ម និងសណ្ឋាគារ សាលាមានវិន័យយ៉ាងមឹងមាត់ ក្នុងការជួយឲ្យសិស្សរីកចម្រើនក្នុង មានសម្ថភាពក្នុងការសិក្សា។ ឆ្នាំសិក្សា២០១៨-២០១៩ និងមានជំនាញ ក្សេតសាស្ត្រ ផ្នែកកសិកម្ម និងផ្នែកសណ្ឋាគារនិងទេសចរណ៍។ សាលាក៏មានផ្តល់កន្លែងស្នាក់នៅសម្រាប់សិស្សមកពីឆ្ងាយ និងអាហារថ្ងៃត្រង់ផងដែរ៕

*ដោយ លី សុវណ្ណា*



សន្ត ដូមីនីកូ សាវីអូ

ដូមីនីកូ សាវីអូ កើតនៅប្រទេសអ៊ីតាលី នៅឆ្នាំ១៨៤២។ កាលគាត់អាយុ៥ឆ្នាំ គាត់ធ្វើជាអ្នកបម្រើអាសនៈ។ នៅពេលអាយុ ១២ឆ្នាំ គាត់ទៅសួរសុខទុក្ខលោកឪពុក យ៉ូហាន បូស្កូ ហើយប្រាប់គាត់ថា គាត់ចង់ធ្វើជាបូជាចារ្យ។ ទាំងពីរនាក់ក្លាយទៅជាមិត្តដ៏ស្និតស្នាល។ ក្រោយមក ដូមីនីកូចូលនៅក្នុងមណ្ឌលយុវជនរបស់លោកឪពុក យ៉ូហានបូស្កូ។មិត្តភក្តិរបស់ដូមីនីកូស្រឡាញ់ចូលចិត្តគាត់ណាស់ ព្រោះគាត់ជាមនុស្សម្នាក់ ដែលមានចិត្តស្លូតបូត និងសុភាពរាបសា។គាត់ខិតខំព្យាយាមរៀនសូត្រខ្លាំងណាស់ ហើយចូលចិត្តអធិដ្ឋាន។ ប៉ុន្តែគាត់មានសុខភាពមិនល្អ ហើយពីរឆ្នាំក្រោយមក គាត់បានត្រឡប់ទៅផ្ទះគាត់វិញ។ ដូមីនីកូតែងតែរក្សាវិន័យខ្លះដែលគាត់បានកត់ត្រានៅក្នុង សៀវភៅរបស់គាត់ នៅពេលដែលគាត់បានទទួលព្រះកាយព្រះគ្រីស្តជាលើកទីមួយគឺ៖

១- ខ្ញុំនឹងទទួលអគ្គសញ្ញាលើកលែងទោស និងអគ្គសញ្ញាព្រះកាយព្រះគ្រីស្តជាញឹកញាប់។

២- នៅក្នុងឱកាសបុណ្យនីមួយៗ ខ្ញុំតមអាហារ និងចែកទ្រព្យសម្បត្តិដល់ជនក្រីក្រ។

៣-ព្រះយេស៊ូ និងព្រះនាងម៉ារីជាមិត្តសម្លាញ់ដ៏ស្និតស្នាលរបស់ខ្ញុំ។

៤-ខ្ញុំសុខចិត្តស្លាប់ប្រសើជាងការប្រព្រឹត្តអំពើបាបណាមួយ។

ប៉ុន្តែ ដូមីនីកូធ្លាក់ខ្លួនឈឺយ៉ាងខ្លាំង។ មុនដូមីនីកូផុតដង្ហើម គាត់និយាយប្រាប់ថា៖ ខ្ញុំយល់ឃើញថា ព្រះយេស៊ូជាសុភមង្គលដ៏ពិតប្រាកដតែមួយគត់។ គាត់បានទទួលមរណភាព ពេលគាត់មានអាយុ១៥ឆ្នាំ។ ក្រោយមក លោកឪពុក យ៉ូហាន បូស្កូ បាននិពន្ធជីវប្រវត្តិរបស់គាត់។ ព្រះសហគមន៍ទទួលស្គាល់ថា ដូមីនីកូជាគំរូសម្រាប់យុវជន ទូទាំងពិភពលោក៕

# គ្រីស្តបរិស័ទហុងកុង តាមរយៈអង្គការគ្រួសារសន្តិភាពបានយកចិត្តទុកដាក់លើការសិក្សារបស់កុមារកម្ពុជា



ថតដោយៈ ប៉ូវ៉ា

យុវជនគ្រីស្តបរិស័ទជាតិហុងកុង បាន ស្ម័គ្រចិត្ត នៅអងការគ្រួសារសន្តិភាព ដើម្បី បណ្តុះបណ្តាលភាសាអង់គ្លេសដល់កុមារ នៅកម្ពុជាចាប់តាំងពីចុងខែកក្កដាមក។ ពួក គេបានរៀបចំការបោះជំរំ រៀនភាសាអង់-គ្លេសរយៈពេលមួយខែ ( Summer Camp ) ដើម្បីជួយឲ្យកុមាររីកចម្រើនផ្នែកភាសា អង់គ្លេសនេះ ដែលជាគ្រឹះអាចជួយខ្លួន ឯងក្នុងការបន្តការសិក្សាក៏ដូចជាការប្រកួត ប្រជែងក្នុងទីផ្សារការងារនាពេលអនាគត ក្នុងបរិបទសម័យទំនើបផងដែរ។

តាមប្រសាសន៍របស់លោក ផាន ប៉ូវ៉ា នាយកអង្គការគ្រួសារសន្តិភាព និងជា តំណាងព្រះសហគមន៍ភូមិភាគកំពង់ចាម ទទួលបន្ទុកដឹកនាំក្រុមនេះបានឲ្យដឹងថា តាមពិតក្រុមនេះជាក្រុមដែលជួយឧបត្ថម្ភ ដល់សិស្សកម្ពុជាដែលខ្វះខាត ដើម្បីបាន រៀននៅវិទ្យាល័យ។ លោកថា ដោយសង្កេត ឃើញថាកូនសិស្ស ដែលបានទទួលការ ឧបត្ថម្ភទាំងនោះខ្សោយខាងផ្នែកភាសា អង់គ្លេសខ្លាំង ទើបយុវជនទាំងនោះស្ម័គ្រចិត្ត មកបង្រៀន និងស្នាក់នៅជាមួយសិស្សយើង ដោយនិយាយភាសាអង់គ្លេសជាមួយគ្នា រយៈពេលមួយខែដើម្បីបណ្តុះបណ្តាល។ លោកបន្តថា ក្នុងរយៈពេលមួយខែនេះ ឃើញថាកុមាររបស់យើងអាចនិយាយ ភាសាអង់គ្លេសបាន ដោយបើកចិត្តចេះ ទំនាក់ទំនងជាមួយមនុស្សប្លែកៗដែរ។

លោកប៉ូវ៉ា បញ្ជាក់ថា គោលដៅរបស់ ពួកគាត់គឺជួយបន្ថែមឲ្យកុមារកម្ពុជា ចេះ ភាសាបរទេសបន្ថែមពីលើភាសាជាតិ ដែល អាចជួយឲ្យពួកគេមានចំណេះដឹងទូលាយ ជាងមុន ដើម្បីងាយស្រួលក្នុងការរកការងារ ផងដែរ។ លើសពីនេះទៅទៀតក្នុងនាមជា គ្រីស្តបរិស័ទលោកថា អ្វីដែលគួរឲ្យកត់ សម្គាល់គឺក្រុមនេះសុទ្ធតែជាកូនអ្នកធូរធារ ប៉ុន្តែពួកគេស្ម័គ្រចិត្តមករស់នៅជាមួយ កូនសិស្សយើង ដែលជាការចែករំលែក ដោយមានចិត្តល្អបែបនេះ បានជួយលើក ទឹកចិត្តខ្ញុំខ្លាំងមែនទែន ដោយសាររាល់ ថ្ងៃខ្ញុំធ្វើការខាងផ្នែកបណ្តុះបណ្តាល និង អភិវឌ្ឍន៍ធនធានមនុស្ស ហើយតាមរយៈ ក្រុមនេះខ្ញុំបានឃើញសេចក្តីស្រឡាញ់ដែល ចេញពីពួកគាត់ច្រើន និងបានឃើញពួក គេជួយកូនសិស្សហើយ កូនសិស្សអាច មានសកម្មភាពរស់រវើក ដែលខុសប្លែកពី សកម្មភាពខ្លះដែលខ្ញុំបានធ្វើកន្លងមក។ ដូច្នេះនៅពេលខ្ញុំរៀនពីពួកគាត់ អាចធ្វើឲ្យ ផ្លូវវិញ្ញាណខ្ញុំមានភាពប្រសើរជាងមុន ដូច ជាការអង្គុយនិយាយជាមួយកូនសិស្សគឺ មានភាពស្និទ្ធស្នាលជាងមុន ព្រោះថាជីវិត ផ្លូវវិញ្ញាណរបស់គ្រីស្តបរិស័ទ នៅពេល ដែលអង្គុយនិយាយជាមួយអ្នកតូចតាច ណាម្នាក់គឺហាក់បីដូចជាអង្គុយនិយាយ ជាមួយព្រះយេស៊ូដែរ។

កញ្ញា Paula Sun ដែលជាយុវជន ស្ម័គ្រចិត្តបានឲ្យដឹងទៀតថា៖ ពួកខ្ញុំទាំង ៥នាក់ មកកម្ពុជាដើម្បីបង្រៀនភាសា អង់គ្លេសដល់កុមារអនុវិទ្យាល័យ និង វិទ្យាល័យ នៅកំពង់ចាមរយៈពេល៣ សប្តាហ៍ និងពីរសប្តាហ៍នេះពួកយើងមក ភ្នំពេញ ដើម្បីមានឱកាសបង្រៀនភាសា អង់គ្លេសដល់កុមារផ្សេងទៀត បន្ទាប់ពី កំពង់ចាម ហើយក៏អាចរៀនពីស្ថានភាព ជីវិតនៅក្រុងនេះផងដែរ។

យុវនារីរូបនេះ បានឲ្យដឹងថានាងមក ទីនេះ( កម្ពុជា ) មកពីចូលចិត្តធ្វើដំណើរ និង ចង់ជួយដល់កុមារ ទើបលោកបូជាចារ្យ នៅហុងកុងបានផ្តល់ឱកាសឲ្យខ្ញុំបានមក បង្រៀនកុមារនៅកម្ពុជាក្នុងពេលវិស្សម-កាលនេះ និងជាពិសេសក៏ចង់ស្គាល់ពី វប្បធម៌ប្រពៃណីក្រៅពីហុងកុង។ តែពេល មកកម្ពុជាបានទទួលបទពិសោធន៍នៃការ ចែករំលែក ។ នាងបន្តថា ឥលូវនេះមាន ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយក្មេងៗ នៅទីនេះ នាំឲ្យចិត្តខ្ញុំសម្រេចថានឹងមក ទីនេះទៀតនាឆ្នាំក្រោយ ដើម្បីតបង្រៀនក៏ ដូចជាការចង់ដឹងពីការអភិវឌ្ឍរបស់ក្មេងៗ ផងដែរ។

ក្រុមយុវជនស្ម័គ្រចិត្តទាំង៥នាក់នេះ មកជួយកុមារនៅប្រទេសកម្ពុជាតាមរយៈ អង្គការគ្រួសារសន្តិភាពជាអង្គការមួយដែល បង្កើតឡើងដោយគ្រីស្តបរិស័ទនៅព្រះ សហគមន៍ភូមិភាគកំពង់ចាមនៅក្នុងឆ្នាំ ២០១៤ ដោយមានអង្គការស្ថានសន្តិភាព ជាដៃគូ ហើយបានជួយឧបត្ថម្ភដល់កម្មវិធី នៅតាមស្ថាប័នកាតូលិកមួយចំនួន ដើម្បី អភិវឌ្ឍន៍ធនធានមនុស្សផងដែរ៕

ដោយ ដាលីស

# ពិធីជួបជុំអតីតនិស្សិត និងនិស្សិតរបស់វិទ្យាស្ថានសន្តប៉ូល

វិទ្យាស្ថាន សន្តប៉ូល បាន រៀបចំការ ជួបជុំ អតីតនិស្សិត និងនិស្សិតរបស់ វិទ្យាស្ថាន កាលពីថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៨ កន្លងទៅ ក្រោមអធិបតីភាព របស់លោកអភិបាល អូលីវីយេ ឆ្មីតអីស្លែរ ស្ថាបនិកនៃវិទ្យាស្ថាននេះ ព្រមទាំងមាន ការចូលរួមពីសំណាក់អតីតនិស្សិត និង និស្សិត សាស្ត្រាចារ្យ ចំនួនប្រមាណជា ៥០០នាក់ ក្នុងនោះក៏មានការចូលរួមពី សំណាក់សិស្សវិទ្យាល័យនានាក្នុងស្រុង ត្រាំកក់ចំនួនប្រមាណ ១៣៥នាក់ផងដែរ។

តាមលោក ផុន សុផល នាយកវិទ្យា-ស្ថានសន្តប៉ូល បានឲ្យថា ការជួបជុំនេះ គឺជាទិវាដ៏មានអត្ថន័យ និងសប្បាយរីក-រាយសម្រាប់ការជួបជុំគ្នារវាងអតីតនិស្សិត សាស្ត្រាចារ្យ និងបុគ្គលិកសិក្សាបច្ចុប្បន្ន ។

លោកបន្តថា ក្នុងពិធីជួបជុំនេះនឹង មានសកម្មភាពជាច្រើន មានជាអាទិ៍៖ សកម្មភាពសប្បុរសធម៌ដល់គ្រួសារក្រីក្រ ប្រកបដោយភាតរភាព។ ការផ្លាស់ប្តូរទាំង ចំណេះដឹង ជំនាញ និងការទទួលខុសត្រូវ តាមរយៈការប្រកួតតស៊ូមតិ។ ការប្រកួត កីឡា ជាមិត្តភាព។ ការប្រកួត ស្នាដៃធ្វើ ម្ហូប។ ការចែករំលែកបទពិសោធន៍នៃ ភាពជោគជ័យ និងបញ្ហាដែល បានជួប ប្រទះរបស់អតីតនិស្សិត សម្រាប់ជាកម្លាំង ជម្រុញទឹកចិត្តយ៉ាងសំខាន់ដល់និស្សិត បច្ចុប្បន្ន និងសិស្សមកពីវិទ្យាល័យ។

ក្នៅពេលល្ងាចក៏មានអាហារសាមគ្គី មានការសម្តែងសិល្បៈ វប្បធម៌ និងការ រាំកម្សាន្តជាមួយគ្នា។ កម្មវិធីបានបញ្ចប់ ដោយជោគជ័យ ប្រកបដោយស្នាមញញឹម ភាតរភាព មិត្តភាព និងភាពស្និទ្ធស្នាល រវាងគ្នានិងគ្នា។

លោកផុន សុផលក៏មិនភ្លេច អំណរ អរគុណដល់អ្នកផ្តួចផ្តើមគំនិតបង្កើតកម្ម វិធីនេះឡើងគឺលោកអភិបាលអូលីវីយេ សាស្ត្រាចារ្យ បុគ្គលិកសិក្សា និងនិស្សិត ដែលបានជួយសម្រួលក្នុងកម្មវិធីទាំងមូល ឲ្យប្រព្រឹត្តទៅដោយជោគជ័យ និងមាន ទំនួលខុសត្រូវខ្ពស់ ។

វិទ្យាស្ថាន ជាគ្រឹះស្ថានអប់រំថ្នាក់ឧត្តម សិក្សា របស់ព្រះសហគមន៍កាតូលិកនៅ កម្ពុជា តែមួយគត់ ដែលសង់ឡើងនៅ កណ្តាលវាលស្រែ ក្នុងភូមិគគី ឃុំតាភេម ស្រុកត្រាំកក់ខេត្តតាកែវ។ វិទ្យាស្ថានមាន បណ្តុះបណ្តាយ ថ្នាក់បរិញ្ញាបត្រ និង បរិញ្ញាបត្ររង។ ថ្នាក់បរិញ្ញាបត្រមានផ្នែក កសិកម្ម ភាសាអង់គ្លេស ព័ត៌មានវិទ្យា ទេសចរណ៍ និងសង្គមកិច្ច។ តាមលោក ផុន សុផល បានបញ្ជាក់ថា និស្សិតដែល បានបញ្ចប់ការសិក្សា ពីវិទ្យាស្ថាន មាន ការងារធ្វើ។ និស្សិតដែលបានបញ្ចប់ការ សិក្សា នៅឆ្នាំ២០១៧ - ២០១៨ មាន ការងារប្រមាណ៩៨% នេះបើតាមការ សិក្សាស្រាវជ្រាវ និងអង្កេតរបស់សាលា៕

# ខួប ៥ឆ្នាំនៃមណ្ឌលយុវពលករ

ការិយាល័យគណៈកម្មការពលករ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានរៀបចំខួប៥ឆ្នាំនៃការបង្កើតឲ្យមានមណ្ឌលយុវពលករ ជាកន្លែងស្នាក់នៅសម្រាប់ យុវជនយុវនារីដែលមកធ្វើការនៅភ្នំពេញដែលមានតម្លៃសមរម្យ និងជាកន្លែងសម្រាប់កម្មករ កម្មការិនីមកជួបជុំពិភាក្សាលើប្រធានបទនានាប្រចាំខែ។

កម្មវិធីខួប៥ឆ្នាំនេះ បានធ្វើឡើងមណ្ឌលយុវពលករក្នុងសង្កាត់ទួលពង្រ ខណ្ឌដង្កោរ រាជធានីភ្នំពេញ ដោយមានកម្មករ កម្មការិនីដែលតែងតែមកជួបជុំនៅទីនេះ រួមជាមួយអតីតយុវកម្មករចូលរួមកាលពីថ្ងៃទី២៦ សីហា ២០១៨នេះ។

ក្នុងកម្មវិធីនេះមានបង្ហាញដល់អ្នកចូលរួមទាំងអស់អំពីប្រវត្តិ និងរូបថតអនុស្សាវរីយ៍រយៈពេលប្រាំឆ្នាំកន្លងមក ព្រមទាំងបានរិះគិតជាក្រុមអំពីបន្ទប់ជួលដែលមានលក្ខណៈស្តង់ដានាពេលអនាគតតាមក្តីស្រមៃរៀងៗខ្លួន ដើម្បីកែលម្អបន្ទប់ជួលនៃមណ្ឌលយុវពលករផងដែរ។

លោកបូជាចារ្យដែលផ្តួចផ្តើមគំនិតឲ្យមានមណ្ឌលយុវពលករ ព្យែរ ឡូរ៉ង់ (សិលា) មានប្រសាសន៍ថា មូលហេតុដែលបើកឲ្យមានមណ្ឌលនេះ គឺដើម្បីឲ្យមនុស្សមួយចំនួនមានកន្លែងរស់នៅប្រសើរជាងដោយចេះរស់នៅជាមួយអ្នកដទៃបន្តិចម្តងៗ។ លោកបន្តថា មណ្ឌលនេះមិនមែនជាផ្ទះដ៏អស្ចារ្យទេ តែសំខានជាងនេះគឺចេះរស់នៅជាមួយអ្នកដទៃដោយមានទំនាក់ទំនងជាមិត្តភាព។

លោកបូជាចារ្យ បញ្ជាក់ទៀតថា ទស្សនវិស័យដើម្បីបង្កើតឲ្យមានមណ្ឌលនេះគឺឃើញអ្នកទាំងអស់គ្នាជាមនុស្សដ៏មានតម្លៃហើយ ព្រះយេស៊ូដែលពួកយើងជឿទុកចិត្តព្រះអង្គក៏ស្រឡាញ់មនុស្សទាំងឡាយដែរ ហើយនៅទីនេះខ្ញុំចាប់អារម្មណ៍ថា មានយុវកម្មករខ្លះៗអាចរស់នៅ ដោយខ្លួនឯងបាន ក៏ប៉ុន្តែបន្ទប់ដែលពួកគាត់រស់នៅមិនសូវមានអនាម័យនោះទេ។ លោកបន្ថែមថា ឥលូវនេះមណ្ឌលនេះគឺសម្រាប់ជួលឲ្យអ្នកទាំងអស់គ្នា ដោយមិនគិតថាអ្នកទាំងអស់គ្នាមកពីណាក្រ ឬមាន នោះទេ គឺសម្រាប់ទាំងអស់គ្នា និងសូមប្រើមណ្ឌលនេះដោយមានអំណរសប្បាយ ចេះទទួលខុសត្រូវ និងមានមិត្តភាពរវាងគ្នានិងគ្នា។

លោកក៏មានសំណូមពរសម្រាប់ពេលអនាគតថា សូមបង្កើតសកម្មភាពខ្លះៗដែលអ្នកទាំងអស់គ្នាចង់ធ្វើ ដើម្បីឲ្យម្នាក់ៗរកឃើញកន្លែងដែលខ្លួនចង់នៅក្នុងជីវិតព្រោះអ្នកទាំងអស់គ្នាជាម្ចាស់កម្ពុជា។

រីឯ លោក យ៉ាន ជីហ្វុង ជាអ្នកសម្របសម្រួលនៅក្នុងមណ្ឌលយុវពលករ និងជាសមាជិកគណៈកម្មការពលករនៃព្រះសហគមន៍ភូមិភាគភ្នំពេញ បានមានប្រសាសន៍ថា ព្រះសហគមន៍អាច មាន មោទភាពនឹងមណ្ឌលយុវពលករនេះ ដោយសារជាមណ្ឌលសម្រាប់យុវពលករជាគំរូ ដែលខុសពីផ្ទះជួល ដោយ មិនមែនជួលដើម្បីប្រាក់ចំណេញទេ តែដើម្បីសម្រួលលើបន្ទុកចំណាយរបស់ពលករដែលមិនមែនជាកូនជ្រូកសន្សំលុយសម្រាប់ម្ចាស់ផ្ទះជួល។

លោកយ៉ានបន្តថា នៅទីនេះយើងជួយឲ្យពួកគាត់មានកន្លែងស្នាក់នៅសមរម្យដែលមានទាំងកម្មវិធីកំសាន្ត កីឡាផងដែរ។ លោកថា សម្រាប់អ្នកដែលមកជួលនៅទីនេះមានបទបញ្ជាផ្ទៃក្នុងដែលជាវិន័យច្បាស់លាស់ ដើម្បីជួយដោះស្រាយបញ្ហាខ្លះដោយចេះទទួលខុសត្រូវក្នុងការងារសម្អាតប្រចាំថ្ងៃ។

កញ្ញា ឈួន សុភាព មកពីខេត្តកំពតបានមកស្នាក់នៅមណ្ឌលយុវពលករ ដើម្បីធ្វើការនៅក្រុមហ៊ុន កូមិន្ទខ្មែរ ខាងផ្នែកសម្រង់តម្លៃ បាននិយាយថា ក្រោយពីមិត្តម្នាក់បានប្រាប់អំពីមណ្ឌលក៏បានដាក់ពាក្យមកស្នាក់នៅទីនេះពីរឆ្នាំមកហើយ។ យុវនារី២៣ឆ្នាំបានបន្តថា ការរស់នៅទីនេះបានផ្តល់នូវភាពកក់ក្តៅ ដោយយើងរស់នៅជាក្រុមដូចបងប្អូនគ្នា ទោះបីយើងមកពីខេត្តផ្សេងគ្នា មកពីគ្រួសារផ្សេងៗគ្នា តែយើងមកទីនេះដោយមានញ៉ាំអាហារ និងមានពលកម្មរួមគ្នាហាក់បីដូចជាបងប្អូនគ្នា។ សុភាពថា ការរស់នៅជុំគ្នានេះជួយឲ្យយល់ដឹងពីអ្នកដទៃ បានរៀនចេះយកចិត្តគេដាក់ក្នុងចិត្តយើងដើម្បីឈ្វេងយល់ពីអ្នកដទៃបានច្រើនជាងមុន។

មណ្ឌលយុវពលករ មានបន្ទប់សម្រាប់ជួលចំនួន៦បន្ទប់ មានផ្ទះបាយរួមហើយយុវពលករដែលចូលមកជួលកន្លែងស្នាក់នៅទីនេះ តម្រូវឲ្យមានការដាក់ពាក្យជាមុនមានទឹកចិត្តចង់រស់នៅជាក្រុម ដើម្បីបង្កើតបរិយាកាសមិត្តភាព និងសន្តិភាព។

ចំពោះថ្លៃចំណាយអ្នកជួលត្រូវបង់ថ្លៃបន្ទប់ចំនួនបួនម៉ឺនរៀលក្នុងមួយនាក់ ក៏ប៉ុន្តែបើសរុបទាំងថ្លៃ អ៊ីនធឺណែត និងទឹកភ្លើង ត្រូវចំណាយប្រហែលមួយនាក់ប្រាំម៉ឺនរៀលប៉ុណ្ណោះ។

តាមប្រសាសន៍របស់លោកយ៉ានបញ្ជាក់ថា បច្ចុប្បន្នមណ្ឌលនេះមានអ្នកជួលសរុប ១១នាក់ ហើយអាចទទួលបន្ថែមចំនួន៤នាក់ទៀតផងដែរ៕

*ដោយ ដាលីស*




ថតដោយ :ដាលីស

# ការស្តាប់ខ្លួនឯង ស្តាប់អ្នកដទៃ ជាមធ្យោបាយដើម្បីអភិវឌ្ឍន៍ខ្លួន

សិក្ខាកាមចំនួន៤៦នាក់មកពីកន្លែងផ្សេងៗបានចូលរួមសិក្ខាសាលាស្តីអំពីការស្តាប់ខ្លួនឯង ស្តាប់អ្នកដទៃ និងការស្វាគមន៍ ដែលរៀបចំឡើងដោយលោកបូជាចារ្យ ហ្វ្រង់ស្វ័រសាវីយ៉េ ឌីម៉ុង និងមានអ្នកស្រី អេលីសាប៉ែត (Elisabeth Kremer) ជាវាគ្មិន មកពីបារាំង ដែលមានរយៈពេល៣ថ្ងៃ ពីថ្ងៃទី៦-៨ សីហា ២០១៨ នៅព្រះវិហារសន្តសិលា និងសន្តប៉ូល សង្កាត់ភ្នំពេញថ្មី រាជធានីភ្នំពេញ។

នៅក្នុងអង្គសិក្ខាសាលានេះ សិក្ខាកាមទាំងអស់បានឈ្វេងយល់អំពីខ្លួនឯង និងអ្នកដទៃ ដោយទុកពេលវេលាដើម្បីរិះគិត និងស្តាប់ខ្លួនឯង ព្រមទាំងរៀនស្តាប់អ្នកដទៃ តាមរយៈការចែករំលែកជាក្រុមតូចៗ និងក្រុមធំផងដែរ។

អ្នកស្រី អេលីសាប៉ែត ជាវាគ្មិនបានមានប្រសាសន៍ថា អ្នកស្រីមកទីនេះមិនមែនដើម្បីមកបង្រៀនទ្រឹស្តីអ្វីនោះទេ តែមកដើម្បីធ្វើជាអ្នកនាំពាក្យ និងបង្ហាញពីវិធីសាស្ត្រនៃទ្រឹស្តីរបស់លោក Roger ដែលជាចិត្តវិទូដ៏ល្បីល្បាញ មកចែករំលែកដល់បងប្អូននៅក្នុងអង្គសិក្ខាសាលាដែលមានរយៈពេលបីថ្ងៃនេះ។

វាគ្មិនអេលីសាប៉ែតក៏បង្ហាញពីទិសដៅនៃអង្គសិក្ខាសាលានេះផ្តោត សំខាន់ទំនាក់ទំនង គឺទំនាក់ទំនងផ្ទាល់ខ្លួន និងជាមួយអ្នកដទៃតាមរយៈការសន្ទនាដោយការជឿជាក់លើគ្នា និងផ្ទាល់ខ្លួនអាចជួយអ្នកដទៃ ឲ្យគាត់ក្លាយជាខ្លួនគាត់បាន និងការទុកចិត្តក្រុម ដើម្បីធ្វើការរួមគ្នា។

លោកបូជាចារ្យ ហ្វ្រង់ស្វ័រសាវីយ៉េ ជាអ្នកសម្របសម្រួល ក៏បានប្រកាសផងដែរថា នេះជាពេលមួយដើម្បីស្គាល់ខ្លួនឯង ស្តាប់ខ្លួនឯង ស្តាប់អ្នកដទៃ ដែលជារបៀបមួយនៅក្នុងចិត្តវិជ្ជាដើម្បីឈ្វេងយល់ពីខ្លួនឯង និងអ្នកដទៃ។

រយៈពេលបីថ្ងៃនៃសិក្ខាសាលា អ្នកស្រីអេលីសាប៉ែត បានពន្យល់ និងណែនាំអំពីរបៀបស្តាប់ខ្លួនឯងដោយទុកពេលវេលាស្តាប់ពីខ្លួនឯង និងរិះគិតនូវរាល់ព្រឹត្តិការណ៍នានាដែលបានកើតមានឡើងនៅក្នុងសង្គមមកថ្លឹងថ្លែង និងរកដំណោះស្រាយ។ អ្នកស្រីបញ្ជាក់ថា ជាទូទៅមនុស្សយើងពេលមានទុក្ខលំបាក គឺតែងតែទៅរកគេជួយដើម្បីផ្តល់យោបល់ ក៏ប៉ុន្តែអ្វីដែលសំខាន់បំផុត គឺខ្លួនយើងផ្ទាល់គួរតែជាអ្នកដោះ-ស្រាយ ព្រោះយើងគឺជាប្រភពដើម។

សិក្ខាកាមមកពីខេត្តតាកែវ លោក ពេជ្រ ពុធ បានឲ្យដឹងថា រយៈពេលបីថ្ងៃនេះពិតជាសប្បាយចិត្តដោយ នេះជាឱកាសមួយដែលយើងត្រូវប្រើពេលវេលាច្រើនដើម្បីស្គាល់ខ្លួនឯងស្គាល់ពីអ្នកដទៃ ដែលកាលពីថ្ងៃដំបូងធ្វើឲ្យមានអារម្មណ៍ថាខ្លាចគ្នា មិនសូវហ៊ាននិយាយស្តី ប៉ុន្តែថ្ងៃបន្តបន្ទាប់មកមានអារម្មណ៍ថាស្និទ្ធស្នាល និងឲ្យតម្លៃគ្នា ហើយចេះគោរពគ្នា។

លោកបន្តថា ការបណ្តុះបណ្តាលរបៀបនេះខ្ញុំក៏ធ្លាប់បានរៀនពីមុនមកហើយដែរ គឺហៅថាការព្យាបាលផ្លូវចិត្តនៅក្នុងក្រុមប្រឹក្សាយោបល់ ដែលត្រូវផ្តល់សេរីភាពឲ្យបុគ្គលនៅក្នុងក្រុមអាចត្រិះរិះ ឬចែករំលែកពីបញ្ហា និងអំពីវិធីសាស្ត្រផ្សេងៗដើម្បីជួយដល់បុគ្គលផ្សេងៗ។

ចំណែកការរៀនដោយគ្មានប្រធានបទនេះគឺអាចជួយឲ្យយើងបើកចិត្តទូលាយដើម្បីនិយាយអំពីជីវិតបុគ្គលម្នាក់ៗដែលមានទំព័រជីវិតច្រើន ព្រោះថាមនុស្សម្នាក់ៗមានបទពិសោធន៍នៅក្នុងជីវិតច្រើន ហើយការចែករំលែកនូវរឿងដែលយើងលាក់ទុកចេញមកក្រៅបានជួយឲ្យយើងអាចរកឃើញដំណោះស្រាយផ្សេងៗពីមិត្តក្នុងក្រុមផងដែរ។

សិក្ខាកាមទាំងនោះបានរៀនពីវិធីយល់ចិត្តអ្នកដទៃដោយការស្តាប់ និងមានមធ្យោបាយបីចំណុចដើម្បីជាជំនួយក្នុងការអភិវឌ្ឍខ្លួនដើម្បីស្តាប់គឺ បង្ហាញពីធាតុពិត ធ្វើខ្លួនយើងនិងអ្នកដែលមកទទួលការប្រឹក្សាមានអារម្មថាលែងឯកា និងមិនធ្វើការវិនិច្ឆ័យភ្លាមៗនោះទេ៕

*ដោយ ដាលីស*



ថតដោយ : ដាលីស

## ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

**មាត្រា ៤៦**

គ្រប់សាលាបង្រៀនបើកបរយានយន្តត្រូវមានលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មសាលាបង្រៀនបើកបរ។

យានយន្ត ត្រូវមានកម្មវិធីសិក្សា និងត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

គ្រប់គ្រូបង្រៀននៅសាលាបង្រៀនបើកបរយានយន្ត ត្រូវមានវិញ្ញាបត្របញ្ជាក់សមត្ថភាពគ្រូបង្រៀន។

បើកបរយានយន្តដែលចេញដោយក្រសួងសាធារណការ ដឹកជញ្ជូន។

លក្ខខណ្ឌ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មសាលាបង្រៀនបើកបរយានយន្ត និងការបង្រៀនបើកបរយានយន្ត និងការប្រឡងយកវិញ្ញាបនបត្របញ្ជាក់សមត្ថភាពគ្រូបង្រៀនបើកបរយានយន្ត ព្រមទាំងកម្មវិធីសិក្សានៅសាលាបង្រៀនបើកបរយានយន្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

ក្នុងករណីក្រសួង មហាផ្ទៃមានសិទ្ធិត្រួតពិនិត្រគ្រប់សាលាបង្រៀនបើកបរយានយន្តទាំងអស់។

**មាត្រា ៤៧**

គ្រប់យានយន្តនៅពេលដាក់ធ្វើឲ្យចរាចរណ៍នៅលើផ្លូវថ្នល់ត្រូវមានបណ្ណសម្គាល់យានយន្ត និងមានពាក់ផ្លាកលេខសម្គាល់យានយន្ត ។

គ្រប់យានយន្តត្រូវចុះបញ្ជីផ្តល់បណ្ណសម្គាល់យានយន្តនិងបំពាក់ផ្លាក់លេខសម្គាល់យានយន្តដោយក្រសួងសាធារណការ និងដឹកជញ្ជូនលើកលែងតែយានយន្តដែលជាទ្រព្យសម្បត្តិរបស់រដ្ឋសម្រាប់បម្រើការសន្តិសុខជាតិ សណ្តាប់ធ្នាប់សង្គម និងការពារជាតិ គ្រប់គ្រងដោយក្រសួងមហាផ្ទៃ ឬក្រសួងការពារជាតិ ។

យានយន្តដែលពុំទាន់ចុះបញ្ជីយានយន្តសុំបណ្ណសម្គាល់យានយន្ត និងបំពាក់ ផ្លាកលេខ ត្រូវផ្ទុកលើយានដែលមានផ្លាកលេខនៅពេលធ្វើចរាចរណ៍។ ចំពោះរ៉ឺម៉កមានទម្ងន់សរុបលើសពី ៧៥០ (ប្រាំពីររយហាសិប) គីឡូក្រាម ត្រូវចុះបញ្ជីរ៉ឺម៉ក ឬសឺមីរ៉ឺម៉កសុំបណ្ណសម្គាល់រ៉ឺម៉ក ឬសឺរ៉ឺម៉កនិងសុំផ្លាកលេខដូចយានយន្តដែរ ។

ក្រសួងសាធារណការ និងដឹកជញ្ជូនត្រូវផ្តល់បញ្ជីស្ថិតិយានយន្តគ្រប់ប្រភេទដែលបានចុះបញ្ជីរួចជូនក្រសួងមហាផ្ទៃមួយខែម្តង។

ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិត្រូបផ្តល់ព័ត៌មានអំពីចំនួនរថយន្តទោចក្រយានយន្ត ត្រីចក្រយានយន្ត ឬគ្រឿងចក្រ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនជូនក្រសួងសាធារណការ ដឹកជញ្ជូន ៣ (បី) ខែម្តងលើកលែងព័ត៌មានសម្ងាត់ដែលពាក់ព័ន្ធនឹងសន្តិសុខជាតិ។

ការចេញផ្លាកលេខសម្គាល់យានជំនិះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៤៨**

គ្រប់ម្ចាស់ហាងលក់យានយន្តគ្រប់ប្រភេទមានកាតព្វកិច្ចបំពេញបែបបទចុះបញ្ជីយានយន្តសុំបណ្ណសម្គាល់យានយន្ត និងសុំផ្លាកលេខសម្គាល់យានយន្តឲ្យបានចប់ឲ្យសព្វគ្រប់មុននិងប្រគល់ឲ្យអ្នកទិញ ។

ការលក់ទិញការធ្វើអំណោយនិងរាល់តម្រង់ផ្សេងទៀតដែលនាំឲ្យមានការផ្លាស់ប្តូរកម្មសិទ្ធិករនៃយានយន្តត្រូវបំពេញសំណុំបែបបទដើម្បីផ្ទេរកម្មសិទ្ធិយានយន្តមិនឲ្យលើសពីរយៈពេល ៩០ (កៅសិប) ថ្ងៃ ម្ចាស់យានយន្តគ្រប់ប្រភេទមានកាតព្វកិច្ចបំពេញបែបបទលុបចេញពីបញ្ជីយានយន្តនូវយានយន្តទាំងឡាយដែលឈប់ប្រើប្រាស់ ។

បែបបទនិងនីតិវិធីនៃការចុះបញ្ជីយានយន្តការផ្តល់ផ្លាកលេខសម្គាល់យានយន្តការផ្ទេរកម្មសិទ្ធិយានយន្ត និងការលុបចេញពីបញ្ជីយានយន្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

(មានតនៅលេខក្រោយ)

# តើជនតំណាងអាណានិគមប៉ុន្មាននាក់ដែលគេត្រូវការដើម្បីបញ្ជូនឲ្យទៅធ្វើអាណានិគមនៅភព ក្រៅប្រព័ន្ធព្រះអាទិត្យដែលជិតបំផុត ?


ថតពីអ៊ីនធឺណែត

អ្នកសិក្សាស្រាវជ្រាវនៃសកលវិទ្យាល័យស្ត្រាប្ចួនៃប្រទេសបារាំង បានព្យាយាមនាំមកនូវចម្លើយសម្រាប់សំនួរជាស្ថិតិសុទ្ធនេះ។

ភពព្រះអង្គារបានផ្តល់ចំណាប់អារម្មណ៍ជាចម្បងបំផុត។ ភពព្រះអង្គារតំណាងឲ្យច្រកទ្វារដែលនៅក្បែរ បើគិតអំពីចម្ងាយអវកាសពី ៥៥លាន ទៅ ៧៥លានគីឡូម៉ែត្រពីផែនដី។ ប៉ុន្តែភពព្រះអង្គារ ឬភពក្រហមបង្ហាញនូវគុណវិបត្តិនៃទំហំ។ វាមិនមែនជាទីជម្រកសម្រាប់មនុស្សជាតិនោះទេ។ និយាយម៉្យាងទៀត អ្នកទស្សនាចរម្នាក់ដែលឈានជើងទៅដល់ជាន់លើភពក្រហមត្រូវរស់នៅក្នុងទីជម្រកគត់មត់ ដែលរង់ចាំនូវដំណោះស្រាយបច្ចេកវិទ្យា ដែលអាចអនុញ្ញាតឲ្យប្រែក្លាយភពក្រហម ទៅជាផែនដីមួយដែលអាចរស់នៅបាន។

ដោយចាកចេញដើម្បីក្តីស្រមៃនេះ ក្រុមអ្នកសិក្សាស្រាវជ្រាវនៃសកលវិទ្យាល័យស្ត្រាប្ចួ បានប្រមើលមើលថា មនុស្សជាតិនឹងអាចទៅតាំងទីលំនៅនៅលើភពនានាដែលមានស្ថានភាពកាន់តែអនុគ្រោះ ហើយប្រហែលជាមិនចាំបាច់ត្រូវការការងារដែលត្រូវប្រើបញ្ញាញាណដ៏សម្បើមដែលមិនអាចវាស់វែងបាននោះដែរ។ ហើយភពមួយក្នុងចំណោមបេក្ខភាពដ៏ប្រសើរបំផុតដើម្បីទទួលពូជមនុស្សជាតិយើង គឺប្រហែលជាភពប្រូស៊ីម៉ា សង់តូរី បេ។ វាគឺជាភពក្រៅប្រព័ន្ធព្រះអាទិត្យ ដែលវិលនៅក្នុងគន្លងជុំវិញផ្កាយ ប្រូស៊ីម៉ា សង់តូរ៉ែដែលមានលក្ខណៈពិសេស ស្ថិតនៅជិតបំផុតនៃប្រព័ន្ធព្រះអាទិត្យរបស់យើង។ ភពដែលនៅក្រៅប្រព័ន្ធ ព្រះអាទិត្យសម្បូរថ្មនេះ មានម៉ាសប្រហាក់ប្រហែលនឹងម៉ាសផែនដី មានគន្លងវិលជុំវិញ ផ្កាយរបស់វាក្នុងតំបន់ដែលអាចផ្តល់ទីជម្រកដល់ជីវិត។ នេះមានន័យថា វាប្រហែលមានសក្តានុពលផ្ទុកនូវទឹកក្នុងសភាពរាវ។

ដូច្នេះក្រុមអ្នកសិក្សាស្រាវជ្រាវក៏បានចោទសួរជាសំណួរថា ឧបមាថា ភពប្រូស៊ីម៉ា សង់តូរី បេ អាចផ្តល់ទីជម្រកដល់មនុស្សបានទៅចុះ តើជនតំណាងអាណានិគមប៉ុន្មាននាក់ដែលគួរតែត្រូវបានគេបញ្ជូនទៅពិភពលោកថ្មីនោះដើម្បីអាចស្ថាបនាវត្តមានមនុស្សជាអចិន្ត្រៃយ៍នៅទីកន្លែងផ្ទាល់?

ចម្លើយគឺមានភាពស្មុគស្មាញ ពីព្រោះទោះបីជាប្រូស៊ីម៉ា សង់តូរ៉ែ គឺជាផ្កាយដែលនៅជិតយើងបំផុតក្តី ក៏វាស្ថិតនៅប្រមាណដល់ទៅ ៤.២២ឆ្នាំពន្លឺពីយើង។ និយាយម៉្យាងទៀត ដើម្បីឈានទៅដល់ផ្កាយនោះជាមួយនឹងល្បឿន ដូចជាយានអាប៉ូឡូ ១១ ដែលមានល្បឿន ៥៥០០គមក្នុង ១ម៉ោង ក៏គេត្រូវការ ១១៤០៨០ឆ្នាំដែរ ទើបទៅដល់ភពក្រៅប្រព័ន្ធព្រះអាទិត្យ ប្រូស៊ីម៉ា សង់តូរីបេ។ វាគឺជារយៈពេលដែលគេចាត់ទុកថា ដូចជា យូរគ្មានអ្វីថ្លែង។ ដូច្នេះតារាវិទូបានជ្រើសរើសយកយានអវកាសសាកល្បងផ្សេងទៀតជាគោល គឺយាន "Parker Solar Probe" ដែលត្រូវបានបាញ់បង្ហោះនៅអំឡុងរដូវក្តៅ ឆ្នាំ២០១៨។ យានអវកាសនេះ គឺយាន F1 ដ៏ពិតប្រាកដ។ យាននេះអាចនឹងមានសមត្ថភាពនឹងហោះហើរយ៉ាងលឿនក្នុងល្បឿន ២០០គីឡូម៉ែត្រក្នុងមួយវិនាទី។ ប៉ុន្តែដើម្បីដល់គោលដៅដែលអាចឲ្យយាននេះទៅដល់ភព ប្រូស៊ីម៉ា សង់តូរី បេ វាក៏ត្រូវចំណាយពេល ៦៣០០ ឆ្នាំផងដែរ។ ដូច្នេះបញ្ហាមួយទៀតរបស់អ្នកវិទ្យាសាស្ត្រគឺថា តើជនតំណាងអាណានិគមប៉ុន្មាននាក់ដែលគួរឡើងទៅលើយាននេះដើម្បីធ្វើដំណើរមួយ ដែលត្រូវចំណាយពេលប្រមាណ ៧៥ ជំនាន់មនុស្សនោះ និងអាចនៅសល់គ្រប់គ្រាន់នៃសែនសម្រាប់អ្នកដំណើរដើម្បីឲ្យពួកគេអាចស្ថាបនានូវអាណានិគមមួយនៅលើផែនដីថ្មីដែលអាចទទួលឲ្យរស់នៅនោះ។ ចម្លើយរបស់អ្នកវិទ្យាសាស្ត្រសម្រាប់សំនួរនេះគឺថា ជនតំណាងអាណានិគម ៩៨នាក់ (ដែលចំនួនស្រីស្មើនឹងបុរស) គឺគ្រប់គ្រាន់ ដើម្បីស្ថាបនាអាណានិគមមួយដោយជោគជ័យ ១០០% ក្នុងការធ្វើដំណើរមួយ ដែលមានរយៈពេល ៦៣០០ ឆ្នាំ។

តើអ្នកវិទ្យាសាស្ត្រធ្វើដូចម្តេចទើបរកឃើញតួលេខនេះ? នេះគឺដោយសារម៉ូដែលគណិតវិទ្យា ដែលមានឈ្មោះថា "មរតក" ដែលប្រើប្រាស់វិធីសាស្ត្រ Monte-Carlo។ វិធីសាស្ត្រនេះអនុញ្ញាតឲ្យអាចណែនាំនូវចំនួនពិតប្រាកដនៃព្រឹត្តិការណ៍ច្រើន ឬតិច ជាប្រហាក់ប្រហែលដូចជាការឆ្លងរោគរាតត្បាត គ្រោះថ្នាក់ ភាពអារគ្មានកូននៃបុគ្គលមួយចំនួន និងមរណភាពជាធម្មជាតិ... បន្ទាប់មកក៏វាយតម្លៃសភាពនៃប្រជាជននៅលើយានអវកាសឆ្លងកាត់តាមពេលវេលា បន្ទាប់ពីមានរឿងជាច្រើនទៀតដែលអាចនឹងកើតមានឡើងដោយនឹកស្មានមិនដល់។ ទាំងអស់គ្នានៅក្នុងមជ្ឈដ្ឋានដែលមានកម្រិតនៃយានដែលមិនអាចនឹងអាចអនុញ្ញាតឲ្យចំនួនប្រជាជនកើនឡើងជារៀងរហូតនោះទេ។ ដូច្នេះរឿងដែលរាប់បញ្ចូលសម្រាប់ភាពសមហេតុផល គឺកាកំហិតចំនួនប្រជាជននៅលើយានអតិបរិមាតែ ៤៥០នាក់ ព្រមទាំងចំនួនកូនគឺឲ្យមានតែបីនាក់ ជាអតិបរមាសម្រាប់ស្ត្រីម្នាក់។

ព្រឹត្តិការណ៍មហន្តរាយអាចកើតរៀងរាល់ ២៥០០ឆ្នាំ។ ដើម្បីឲ្យកាន់តែមានប្រាកដភាព អ្នកវិទ្យាសាស្ត្របានផ្តល់នូវរូបមន្តអំពីការមកដល់នូវព្រឹត្តិការណ៍មហន្តរាយ ដែលនាំទៅដល់ការស្លាប់ជាទ្រង់ទ្រាយធំ នៅរៀងរាល់ ២៥០០ឆ្នាំ ម្តង ដើម្បីមើលថា តើប្រជាជនទោះជានៅក្នុងករណីណា ក៏ដោយអាចនឹងកកើតឡើងវិញ។ យោងតាមអ្នកសិក្សាស្រាវជ្រាវទាំងនេះ បើចំនួនគូស្វាមីភរិយានៅសល់តែ ២៥គូ គឺអាចនាំទៅដល់ការបរាជ័យនៃបេសកកម្មធ្វើអាណានិគមអស់ ៥០%។ វាគឺគ្រាន់ជាតួលេខស្ថិតិសុទ្ធ ហើយគេក៏មិនទាន់បានគិតទៅដល់ចំនួនដ៏ពិតប្រាកដនៃកត្តាផ្សេងៗ ដែលជាគន្លឹះ មានជាអាទិ៍ការប្រែប្រួលហ្សែន ដោយត្រូវបានបង្កើនល្បឿនដោយការទទួលរងជាតិវិទ្យុសកម្មពីអវកាសនៅចន្លោះតារា។ ចំណែកការប្រែប្រួលដែលជះឥទ្ធិពលទៅលើលទ្ធភាពបង្កកំណើត ឬការស្លាប់ នៅមិនទាន់យល់ដឹងអស់នៅឡើយ។ ការសិក្សាក៏មិនទាន់គិតទៅដល់ឥទ្ធិពលដែលការឈប់ជាយថា ហេតុដើម្បីស្វែងរករកភពផែនដីថ្មី ដែលនៅទីនោះមនុស្សភពផ្កាយបានតាំងទីលំនៅរួចហើយនោះ។

ទោះបីទាំងនេះគឺជាការឧបមាន។ ប៉ុន្តែវាក៏ជាក្តីស្រមៃ ក៏ដូចជា គោលដៅពិតប្រាកដនៅថ្ងៃណាមួយរបស់អ្នកវិទ្យាសាស្ត្រ៕

# ព្រះសហគមន៍កាតូលិក យកចិត្តទុកដាក់លើជនរងគ្រោះដោយអគ្គីភ័យ


ថតដោយ : លីហៀង

មណ្ឌលសកម្មភាពភ្នំពេញខាងជើងនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានចែកអំណោយជាលើកទីពីរដល់ជនរងគ្រោះដោយសារអគ្គីភ័យចំនួន ៦៧ គ្រួសារ កាលពីថ្ងៃទី២៥ កក្កដា ២០១៨ នៅព្រះវិហារសន្តយ៉ូសែប(ផ្សារតូច) ក្នុងខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយមានលោកប៉ូល រឿង ធ័ត្រសិរី និងលោកកាលេណានីឆារលេសជាបូជាចារ្យតំណាងព្រះសហគមន៍ និងតំណាងគ្រីស្តបរិស័ទមួយចំនួនចូលរួមផងដែរ។

ក្នុងការសំណេះសំណាលដែលជាកិច្ចស្វាគមន៍លោកប៉ូល រឿង ធ័ត្រសិរី ជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពភ្នំពេញខាងជើង បានថ្លែងលើកទឹកចិត្តថា ទោះបីជាយើងបានអស់ពីខ្លួនពិតមែន តែនេះជាជំហានសំខាន់ដើម្បីឲ្យយើងបន្តដំណើរទៅមុខទៀតដូចដែលលោកធ្លាប់មានបទពិសោធន៍ភ្លើងឆេះផ្ទះកាលពីលោកនៅជានិស្សិតទេវវិទ្យាល័យ និងសំណូមពរដល់អស់អ្នកដែលមកទទួលអំណោយ ឲ្យយល់ពីទឹកចិត្តអ្នកដែលបានចូលរួមចែករំលែកទោះបីជាតិចតួច ក៏ប៉ុន្តែជាទឹកចិត្តដែលពួកគាត់ដែលជាអ្នកក្របាននឹកដល់បងប្អូននៅគ្រាលំបាកដើម្បីជាកម្លាំង ហើយនេះជាជីវិតនៅក្នុងសង្គម។ លោកថា ព្រះសហគមន៍ទោះបីមានឋានៈ និងជាតិសាសន៍ខុសគ្នាតែអាចជួយគ្នាទៅវិញទៅមកបាន។

រីឯលោកបូជាចារ្យជំនួយនៃមណ្ឌលសកម្មភាពភ្នំពេញខាងជើង កាលេ ណានីឆារលេសបានមានប្រសាសន៍ថា នៅពេលដែលបានឮថាមានភ្លើងឆេះនៅមាត់ទន្លេ លោកអាណិតមែនទែនព្រោះមិនបានយកបានអ្វីទាំងអស់ តែមិនមានបាត់បង់ជីវិតសោះ។ លោកថាព្រះជាម្ចាស់បានការពារជីវិតយើង ហើយពេលណាយើងមានកម្លាំងយើងអាចកសាងជីវិតយើងឡើងវិញបាន និងសូមព្រះជាម្ចាស់ជួយការពារបងប្អូនបន្រទៅទៀត។

ជនរងគ្រោះសុខ ភារម្យ បានប្រាប់ថា ឥឡូវនេះជាគ្រាដែលក្រ ទោះបីតិចតួចក្តី តែយើងអរគុណដែរព្រោះជាពេលអាសន្នហើយ។ លោកថា យើងបានទទួលពីសហគមន៍ផ្សេងៗ និងយើងសូមអរគុណច្រើន ហើយគ្មានអីត្រូវអរគុណជាងពេលនេះទេ ព្រោះទីមួយយើងអត់ផង ទីពីរត្រូវការធ្វើផ្ទះផង និងទីបីទឹកកាន់តែឡើងធំផង ដូច្នេះម្នាក់ៗត្រូវខំស្រូតធ្វើផ្ទះឲ្យទាន់មុនទឹកលិចព្រោះពេលនេះភ្លៀងក៏ភ្លៀង។

លោកសុភាជាអ្នករត់ម៉ូឌុបដែលរងគ្រោះដោយភ្លើងឆេះ បាននិយាយថាព្រះសហគមន៍បានជួយគ្រួសារខ្ញុំដែលគ្មានចំណូលច្រើននៅក្នុងគ្រាអាសន្ននេះ ខ្ញុំសូមអរគុណច្រើនទាំងអ្នកដែលនៅប្រទេសវៀតណាម និងនៅកម្ពុជានេះ ជាពិសេសអ្នកក្រដែលមានចិត្តសប្បុរសធម៌ដែលបានជួយដល់ក្រុមគ្រួសារខ្ញុំនិងអ្នកភូមិខ្ញុំនៅពេលដែលយើងកំពុងលំបាកក្នុងជីវភាពដោយភ្លើងឆេះផ្ទះអស់រលីងដោយគ្មានសង្ឃឹម ប៉ុន្តែសប្បុរសជនទាំងនោះបានជួយសព្វបែបយ៉ាងដើម្បីឲ្យមានជីវិតរស់នៅ។ លោកសូមជូនពរដល់ម្ចាស់ជំនួយទាំងអស់ឲ្យមានសុខភាពល្អ និងរកស៊ីមានបានទាំងអស់គ្នា។

តាមប្រសាសន៍របស់លោកបូជាចារ្យសីរី បានឲ្យដឹងថានេះជាជំហ៊ានទីពីរក្រោយពីព្រះសគមន៍បានជួយនូវជំនួយខាងក្រៅដែលសំដៅលើការផ្គត់ផ្គង់លើសម្ភារនៃតម្រូវការដូចជាការសាងសង់ផ្ទះ ឬសម្ភារទូទៅ។ លោកថាកាលពីដំណាក់កាលទីមួយគឺបន្ទាន់យើងជួយជាគ្រឿងឧបភោគ រីឯជំហ៊ានទីពីរយើងនឹកដល់ការសាងសង់ដែលយើងបានប្រមូលថវិកាហ្នឹងដើម្បីជួយគេ និងជំហ៊ានតទៅមុខទៀតគឺផ្លូវវិញ្ញាណដែលមានសារៈសំខាន់ ហើយយើងដើរជាមួយគាត់ដើម្បីឲ្យគាត់មានការតស៊ូនៅក្នុងជីវិតឡើងវិញដោយប្រកាសដំណឹងល្អរបស់ព្រះជាម្ចាស់ តាមរយៈគណៈកម្មការសង្គហៈនិងគ្រីស្តបរិស័ទ។

ថវិកាទាំងនោះបានមកពីបងប្អូនខ្លះដែលមានលុយតិចតួចបានប្រមូលគ្នា និងជួយជាទឹកសុទ្ធ ហើយព្រះសហគមន៍បឹងទំពុនក៏បានប្រមូលប្រាក់ជង្វាយកាលពីថ្ងៃអាទិត្យបានជាង ៤០០ដុល្លា និងជនជាតិថៃមួយចំនួនផងដែរ។ ក្នុងថ្ងៃនេះដែរជនរងគ្រោះទាំងនោះបានទទួលថវិការក្នុងមួយគ្រួសារ៤០ដុល្លារួមជាមួយទឹកសុទ្ធ ត្រីខ មី និងសម្លៀកបំពាក់មួយចំនួនដែរ។

គួររំឭកផងដែរថា ប្រជាពលរដ្ឋចំនួន ៦៧គ្រួសារនេះ ត្រូវរងគ្រោះដោយអគ្គីភ័យដែលបានលេបត្របាក់យកផ្ទះអស់៦៤ខ្នង រួមទាំងទ្រព្យសម្បត្តិត្រូវវិនាសទាំងស្រុង នាព្រលឹមថ្ងៃទី នៅភូមិមិត្តភាព សង្កាត់ឫស្សីកែវ រាជធានីភ្នំពេញ។ ក្រោយមកជនរងគ្រោះទាំងនោះ បានទទួលអំណោយពីសប្បុរជសជននានាមានដូចជា អង្ករ គ្រឿងឧបភោគបរិភោគ ភួយ កន្ទេល និងតង់ជាដើម៕

ដោយ ដាលីស

# ការត្រាស់ហៅរបស់ព្រះជាម្ចាស់ខុសៗគ្នា ត្រូវស្តាប់ សង្ឃឹម និងអធិដ្ឋាន

ព្រះសហគមន៍ភូមិភាគភ្នំពេញបានប្រារព្ធទិវា នៃការត្រាស់ហៅប្រចាំខែលើកទី៧២ នៅអារ៉ាមដូនជីសម្ងាត់ ក្នុងស្រុកអង្គស្នួលខេត្តកណ្តាល ដោយមានលោកអភិបាលអូលីវីយេ ដ្មឹតអីស្លីរ៉ែជាអធិបតី និងមានគ្រីស្តបរិស័ទចូលរួមជាច្រើននាក់មកពីតាមតំបន់មួយចំនួន។

នៅក្នុងធម្មទេសនា លោកអភិបាលអូលីវីយេ មានប្រសាសន៍ថា ព្រះយេស៊ូបានណែនាំឲ្យមនុស្សជាច្រើនមានជីវិតថ្មី "គឺឲ្យមនុស្សម្នាក់ដែលភ្ជាប់ជាមួយព្រះយេស៊ូរកឃើញតម្លៃនៃជីវិត រកឃើញអត្ថន័យនៃជីវិត រកឃើញអ្វីដែលជាទ្រព្យសម្បត្តិនៅក្នុងជីវិតរបស់គាត់"។

លោកអភិបាលមានប្រសាសន៍ទៀតថា មូលហេតុចម្បងដែលព្រះយេស៊ូណែនាំគេឲ្យទទួលជីវិតថ្មី គឺដោយសារព្រះយេស៊ូឈ្វេងយល់ជំនឿរបស់អ្នកទាំងនោះ។ ហើយព្រះអង្គបានព្យាបាលមិនត្រឹមតែរូបកាយ តែសំខាន់គឺអ្វីដែលនៅក្នុងដួងចិត្តរបស់ពួកគេ។ ដោយហេតុនេះហើយ ព្រះយេស៊ូណែនាំឲ្យមនុស្សម្នាក់អាចបំពេញតួនាទីរបស់គេផ្ទាល់នៅលើផែនដីនេះ។

លោកអភិបាលបន្ថែមថា ព្រះជាម្ចាស់ជ្រើសរើសយើង ទោះបីពេលខ្លះយើងមិនដឹង ប៉ុន្តែយើងនៅមានសង្ឃឹមមួយ សេចក្តីត្រូវការមួយ សេចក្តីស្រេកឃ្លានមួយ ដែលណែនាំឲ្យព្រះយេស៊ូអាចចូលបាននៅក្នុងខ្លួនរបស់យើង។ គឺដើម្បីឲ្យយើងភ្ញាក់ស្មារតី និងទទួលស្គាល់ការត្រាស់ហៅរបស់យើងម្នាក់ៗ។

លោកអភិបាលក៏បានបញ្ជាក់ថា "ការត្រាស់ហៅរបស់មនុស្សគឺខុសៗគ្នា តែការត្រាស់ហៅណែនាំឲ្យយើងមានអំណរសប្បាយ។ ហើយការអធិដ្ឋាន និងការប្រកាសដំណឹងល្អគឺត្រូវរួមដំណើរជាមួយគ្នាជានិច្ច។ យើងអត់មានកំលាំងដើម្បីប្រកាសដំណឹងល្អ ប្រសិនបើយើងមិនរកឃើញប្រភពនៃជីវិតនៅក្នុងព្រះយេស៊ូជាព្រះគ្រីស្ត នៅក្នុងភាពសម្ងាត់នៃការអធិដ្ឋានក្នុងជីវិតរបស់យើង"។

ជាមួយគ្នានេះ ដែរលោកអភិបាលសូមឲ្យយុវជនដែលកំពុងស្វែងរកការត្រាស់ហៅរបស់ព្រះជាម្ចាស់ ខិតខំយកចិត្តទុកដាក់ស្តាប់ព្រះសូរសៀងរបស់ព្រះអង្គ ដើម្បីនាំដំណឹងល្អដល់ប្រជាជនកម្ពុជា៕


ថតដោយ: លី សុវណ្ណា

# សម្តេចប៉ាបអធិដ្ឋានជូនជនរងគ្រោះដោយទឹកជំនន់នៅឥណ្ឌា

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃអាទិត្យ ដើមសប្តាហ៍នេះបានដឹកនាំធម្មយាត្រាមួយ នៅទីលានសន្តសិលា ដោយនៅក្នុងឱកាសនោះ សម្តេចប៉ាប ក៏បានជំរុញឲ្យគ្រីស្តបរិស័ទជួយអធិដ្ឋាន ជូនជនរងគ្រោះដោយទឹកជំនន់នៅឥណ្ឌា។

បណ្តាញព័ត៌មានវ៉ាទីកង់បានអះអាងថា សម្តេចប៉ាបបានសម្តែងនូវសមាណចិត្ត ដ៏ក្រៀមក្រំ ចំពោះគ្រោះមហន្តរាយធម្មជាតិដែលបានកំពុងតែកើតមានឡើងនៅ រដ្ឋកេរ៉ាឡា ប្រទេសឥណ្ឌា កាលពីពេលថ្មីៗនេះ។

សម្តេចប៉ាប បានថ្លែងរំលែកទុកជូនជនរងគ្រោះ ដោយប៉ះពាល់ដល់ជីវិត ជាពិសេស គឺអ្នកដែលនៅរស់រៀនមានជីវិត ប៉ុន្តែពួកគេកំពុងតែប្រឈមមុខនឹងកង្វះខាតទីជម្រក ខណៈដែលភ្លៀងនៅតែបន្តធ្លាក់មក នៅក្នុងរដ្ឋនៃប្រទេសឥណ្ឌាមួយនេះ។ គ្រោះធម្មជាតិដែលកំពុងតែកើតមាននៅរដ្ឋកេរ៉ាឡានេះ ត្រូវបានគេដឹងថា បានបង្កឡើងដោយជំនន់ទឹកភ្លៀង ដែលបណ្តាលឲ្យមានទឹកជំនន់ បំណាក់ដី ដែលបានសម្លាប់ជីវិតមនុស្ស ហើយខ្លះបាត់ខ្លួន និង បានធ្វើឲ្យពលរដ្ឋឥណ្ឌានៅក្នុងរដ្ឋនេះជាច្រើន គឺបាត់បង់ទីជំរក បំផ្លិចបំផ្លាញផលដំណាំ។

សម្តេចប៉ាបក៏បានបង្ហាញនូវក្តីរំពឹងថា សហគមន៍អន្តរជាតិ នឹងយកចិត្តទុកដាក់ ដល់កម្មវិធី និងសង្គ្រោះនានា ដើម្បីជួយដល់ប្រជាពលរដ្ឋដែល កំពុងតែមានបញ្ហានៅក្នុងរដ្ឋនោះ៕

# សម្តេចប៉ាប៖ ការចូលអភិបូជា និងសន្ធា គឺជារឿងដ៏សំខាន់សម្រាប់គ្រីស្តបរិស័ទ

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា លើកទឹកចិត្តដល់គ្រីស្តបិរស័ទឲ្យចូលរួម ពិធីថ្វាយអភិបូជា និងទទួលព្រះកាយគឺសំខាន់ណាស់។

សម្តេចប៉ាបបានថ្លែងថា ការចូលរួមពិធីថ្វាយអភិបូជា និងការទទួលនូវ ព្រះកាយ គឺជាចំណុចមួយ ដ៏ចាំបាច់សម្រាប់គ្រីស្តបិរស័ទ ដោយសារតែនេះ គឺជាការទទួលចិត្ត និងរក្សាគំនិត នៅក្នុងការរស់នៅជាមួយនឹងព្រះគ្រីស្ត ដែលជាអង្គប្រែក្លាយយើង ប្រែក្លាយទឹកដីរបស់យើង និងជួយឲ្យយើងទៅកាន់ឋានព្រះបរមសុខ។

តាមវ៉ាទីកង់ញូវ សម្តេចប៉ាប បានថ្លែងថា នៅក្នុងអង្គនៃព្រះគ្រីស្ត គឺព្រះយេស៊ូ គឺជាតំណាងឲ្យព្រះគ្រីស្ត។ សម្តេចប៉ាបបានថ្លែងទៀតថា អស់អ្នកដែលទទួលព្រះកាយ គឺជាអ្នកដែលបើកចិត្តបើកគំនិត ឲ្យទ្រង់គង់នៅជាមួយ ហើយចូលរួមចែករំលែករាល់ទុក្ខលំបាក និងឧបសគ្គទាំង ឡាយ ដែលយើងទាំងអស់គ្នាបានកំពុងតែប្រឈម។

សម្តេចប៉ាបបានថ្លែងទៀតថា អភិបូជា គឺប្រៀបបានជាច្រកនៃការបើកទ្វារឋានព្រះបរម សុខ ហើយព្យាយាមណែនាំគ្រីស្តបរិស័ទ ឲ្យប្រព្រឹត្តតែអំពើល្អ អំពើកុសល់ នៅលើលោកិយនេះ៕

# សម្តេចប៉ាបស្វាគមន៍យុវជននៅវ៉ាទីកង់ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ

កាលពីថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៨ បានធ្វើជាអធិបតីភាពនិងចូលរួមជាមួយនឹងយុវជននៅក្នុងចំនួនដ៏ច្រើន ដែលបានជួបជុំគនា ដើម្បីអធិដ្ឋាននៅពេលថ្ងៃត្រង់។

បណ្តាញព័ត៌មានហ្សីណែតបានរាយការណ៍ថា នៅក្នុងអំឡុងពេលនោះ គឺមានគ្រីស្តបរិស័ទចូលរួមប្រមាណជា ៩០.០០០នាក់ ដោយនៅក្នុងនោះ គ្រាន់តែយុវ ជនគឺមានចំនួនរហូតដល់ទៅ ៧០.០០០នាក់ ដោយពួកគេមកពីព្រះសហគមន៍ផ្សេងៗនៅក្នុងប្រទេសអ៊ីតាលី ជាពិសេស គឺមកពីទីក្រុងរ៉ូមតែម្តង ។

គួររំលឹកថា កម្មវិធីនេះ គឺជាផ្នែកមួយនៃពិធីបញ្ចប់ធម្មយាត្រា ដែលបានចូលរួមដោយ យុវជនប្រមាណជា ៤០.០០០នាក់ ដែលបានចាប់ផ្តើមតាំងតែពីថ្ងៃទី០៣ ខែសីហា មក ដោយសម្តេចប៉ាបក៏បានចូលរួមផងដែរ ប៉ុន្តែ គឺនៅល្ងាចថ្ងៃទី ១១ ខែសីហា នៅមុនពេលជួបជុំអធិដ្ឋាននៅថ្ងៃទី ១២ កន្លងទៅនេះ ។

នាឱកាសនោះ សម្តេចប៉ាប បានចូលរួមប្រាស្រ័យទាក់ទងជាមួយពួកគេដោយផ្ទាល់ ដោយពួកគេបានសួរហើយ សម្តេចប៉ាប បានឆ្លើយសំណួរជាច្រើន នៅក្នុងភាពមួយដ៏ស្និតស្នាល រាក់ទាក់បំផុត ហើយក៏សប្បាយរីករាយបំផុតផងដែរ ហើយសម្តេចប៉ាបបានជំរុញឲ្យពួកគេបន្តធ្វើទំនាក់ទំនងល្អបែបនេះជាមួយនឹងលោកបូជាចារ្យ និងបងស្រីនានា ឲ្យបានមានភាពរីករាយស្និតស្នាលដូចជាពេលនេះ។

សម្តេចប៉ាបបានថ្លែងថា យុវជនគួរតែជាដៃគូ ដ៏មានប្រសិទ្ធិភាពរបស់បូជាចារ្យ និងបងស្រី ដើម្បីប្រកាសដំណឹងល្អ៕

# សម្តេចប៉ាប៖ ការជ្រមុជទឹក មានទិដ្ឋភាពសំខាន់តែពីរទេ

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានរំលឹកប្រាប់ជាថ្មីដល់គ្រីស្ត-បរិស័ទទាំងអស់ថា ការជ្រមុជទឹក គឺជាការសន្យាដែលផ្សារភ្ជាប់នឹងទិដ្ឋភាពនៃសាសនាចំនួនពីរធំៗ។

ថ្លែងទៅកាន់គ្រីស្តបរិស័ទ ដែលបានចូលរួមពិធីធ្លងធម្មយាត្រាមនុស្ស ៩០.០០០នាក់ នៅទីលានសន្តសិលា នៅព្រឹកមិញនេះ សម្តេចប៉ាប បានថ្លែងថា ខ្លឹមសារនៃការសន្យា ដើម្បីទទួល បានអត្តសញ្ញាជាគ្រីស្តបរិស័ទ ឬដែលគេហៅថា ជ្រមុជទឹកនេះ គឺមានពីរ គឺទីមួយបោសសំអាតសារតាំងនិងចិត្តគំនិតសៅហ្មងទាំងឡាយ ហើយទីពីរគឺការប្រតិបត្តិតែអំពើល្អ និងអំពើកុសលនានា។

សម្តេចប៉ាបបានថ្លែងថា នេះគឺជាពិធីដើម្បីប្រកាសអំពីការបើកចិត្តបើកគំនិតជាផ្លូវការ ទទួលយកនូវព្រះជាម្ចាស់ ហើយជាការអះអាងបញ្ជាក់ព្រះជាម្ចាស់ថា ត្រូវតែរស់នៅប្រកបដោយ អំពើល្អសុច្ចរិត។ សម្តេចប៉ាបបានព្យាយាមពន្យល់គ្រីស្តបរិស័ទថា ចំណុចទីមួយនេះគឺថា គ្រីស្តបរិស័ទត្រូវតែនិយាយាថាទេ ចំពោះការល្បួងទាំងឡាយពីសារ-តាំង ហើយត្រូវតែធ្វើខ្លួនឲ្យឆ្ងាយពីអំពើបាបទាំងឡាយ រស់នៅប្រកបដោយភាពទៀតត្រង់ ឆ្ងាយពីអំពើអយុត្តិធម៌ រស់នៅឆ្ងាយពីកំហឹង ។ល។

ដោយឡែកចំណុចទីពីរវិញ នោះ គឺថា នៅក្នុងនាមជាគ្រីស្តបរិស័ទ គឺមិនត្រូវអៀនប្រៀន នឹងការធ្វើខ្លួនតាមអំពើល្អ ។ សូមកុំធ្វើខ្លួន ប្រៀបនឹងសាតាំង ត្រូវតែ ចេះវិភាគ និងឲ្យដឹងថា អ្វីទៅជាអំពើល្អ គឺត្រូវរស់នៅ ដោយគ្មានការស្អប់ អ្វីដែលមាន គឺមានតែការលើកលែងព្យាយាមរស់នៅដោយសន្តិភាពគ្មានការស្អប់ការគុំគួន ។ល។

# សម្តេចប៉ាបបញ្ជូនសារលិខិតរំលែកទុក្ខជូនជនរងគ្រោះដោយគ្រោះរញ្ជួយដីនៅឥណ្ឌូនេស៊ី

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបញ្ជូនតេឡេក្រាមរំលែកទុក្ខមួយផ្ញើរជូនជនរងគ្រោះដោយសារ តែគ្រោះរញ្ជួយដីនៅក្នុងប្រទេសឥណ្ឌូនេស៊ី។ នៅក្នុងសារនោះ សម្តេចប៉ាបបានបង្ហាញនូវភាពសោកស្តាយ ចំពោះគ្រោះមហន្តរាយដែល បណ្តាលមកពីគ្រោះរញ្ជួយដីកម្រិត ៧រ៉េចទ័រ កើតមាននៅលើកោះ លំបុក ដែលជារមណីដ្ឋានមួយនៅក្នុងឥណ្ឌូនេស៊ី និងកោះបាលី។

សម្តេចប៉ាបបានបញ្ជាក់នៅក្នុងតេឡេក្រាមនោះថា នេះគឺជាគ្រោះថ្នាក់ដែលបណ្តាលមកពី គ្រោះធម្មជាតិដ៏ធ្ងន់ធ្ងរ ហើយបានអះអាងថា សម្តេចប៉ាបកំពុងតែអធិដ្ឋានដើម្បីសុំឲ្យបណ្តាអ្នករបួសឆាប់ជា ហើយឲ្យគ្រួសារជនរងគ្រោះដែលជួបហេតុការណអកុសល់ណាមួយ គឺឲ្យឆាប់រសាយចិត្ត។

គ្រោះមហន្តរាយនេះ បានសម្លាប់មនុស្ស ៩៨ នាក់ ខណៈដែលអាគារ សាធារណៈ ផ្ទះសម្បែង ប្រជាពលរដ្ឋរងរបួសក៏ច្រើន ហើយប្រជាពលរដ្ឋជាច្រើននាក់ គឺគ្មានទីជម្រក ។

សម្តេចប៉ាបក៏បានអំពាវនាវ សុំឲ្យនាំគ្នាចូលរួមបរិច្ចាកឈាម ដើម្បីជួយជនរងគ្រោះរបួស ដែលត្រូវការឈាមដើម្បីសង្គ្រោះជីវិតរបស់ពួកគេ។ ក្រៅពីប្រជាពលរដ្ឋគ្រួសារទេសចរណ៍ ក៏ត្រូវបានជំរុញឲ្យមានការជម្លៀសរកកន្លែងសុវត្ថិភាព ហើយប្រធានាធិបតីនៅក្នុងប្រទេសនេះបានជំរុញឲ្យអាជ្ញាធរបង្កភាពងាយស្រួលឲ្យពួកគេមានឱកាសងាយស្រួលត្រឡប់ទៅប្រទេសគេវិញ៕

# ពិសាគ្រឿងស្រវឹងញឹកញាប់ងាយបង្កជំងឺខ្សោយខួរក្បាល



ផតពីអ៊ីនធឺណែត

ការពិសាច្រើន និងទៀងទាត់នៃស្រាបង្កើនបីដងនៃការប្រឈមមុខនៃជំងឺខ្សោយខួរក្បាល ជាពិសេសកើតឡើងទាំងវ័យក្មេង។ បើគេនិយាយអំពីការខ្សោយខួរក្បាលនៅវ័យក្មេង គឺនៅមុនអាយុ ៦៥ឆ្នាំ។ នេះបើតាមការសិក្សាមួយដែលមានមូលដ្ឋានគ្រឹះយកចេញពីទិន្នន័យនៃមន្ទីរពេទ្យនៅប្រទេសបារាំង។

យោងតាមអង្គការសុខភាពពិភពលោកបានឲ្យដឹងថា មនុស្សប្រមាណ ៤៧លាននាក់បានទទួលរងជំងឺខ្សោយខួរក្បាលនៅក្នុងពិភពលោក ហើយប្រមាណពី ៦០%ទៅ ៧០% ឈានទៅដល់ទទួលរងជំងឺវង្វេង។

នៅក្នុងករណីនៃការទទួលទានស្រាបៀរនៅកម្រិតមធ្យម (រហូតដល់ ៣កែវ ស្តង់ដារសម្រាប់បុរស និង២ កែវ សម្រាប់ស្ត្រី) ភាគច្រើននៃការសិក្សាមុនៗ ធ្លាប់បានសន្និដ្ឋានអំពីទំនាក់ទំនងដ៏មានសារៈប្រយោជន៍ជាមួយនឹងសុខភាពស្មារតី ទោះបីជាវាហាក់ដូចជាពាក់ព័ន្ធនឹងការធ្វើឲ្យរបួសរចនាសម្ព័ន្ធខួរក្បាល ទោះបីជាពិសារក្នុងកម្រិតសមល្មមនៃស្រា ដែលនេះគឺជាការចង្អុលបង្ហាញរបស់អ្នកនិពន្ធនៃការសិក្សា។ បើក្នុងករណីនៃការពិសារគ្រឿងស្រវឹងច្រើនលើសលុប ដែលកំណត់ដោយអង្គការសុខភាពពិភពលោក និងភ្នាក់ងារអ៊ឺរ៉ុបនៃឱសថ គឺយ៉ាងហោចណាស់ ៦០ក្រាម នៃជាតិអាកុលសុទ្ធក្នុងមួយថ្ងៃសម្រាប់បុរស និង៤០ក្រាម នៃជាតិអាកុលសុទ្ធក្នុងមួយថ្ងៃសម្រាប់ស្ត្រី។ ភាគច្រើននៃការសិក្សារស្រាវជ្រាវបានបង្ហាញអំពីឥទ្ធិពលអវិជ្ជមានទៅលើសុខភាពស្មារតី និងការប្រថុយប្រថានកើនឡើងសម្រាប់ជំងឺខ្សោយខួរក្បាល។ ប៉ុន្តែវិធីសាស្ត្រដែលគេប្រើប្រាស់សម្រាប់ពិសោធន៍ រារាំងដ៏សេចក្តីសន្និដ្ឋានចុងក្រោយសម្រាប់ប្រធានបទនេះ។ នេះបើយោងតាមអ្នកនិពន្ធការសិក្សា ពីព្រោះមនុស្សប្រមឹកតែងតែបដិសេដនៅក្នុងករណីភាគច្រើនដើម្បីនឹងចូលរួមជាមួយនឹងការសិក្សាស្រាវជ្រាវវេជ្ជសាស្ត្រទាំងឡាយ។

៥៧% នៃករណីខ្សោយខួរក្បាលមុនវ័យជាប់ពាក់ព័ន្ធផ្ទាល់នឹងគ្រឿងស្រវឹង។ ដើម្បីឱបក្រសោបជុំវិញបញ្ហានេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់ព័ត៌មានដែលមានប្រភពពីប្រព័ន្ធព័ត៌មាននៃសកម្មភាពវេជ្ជសាស្ត្រ ដែលមានព័ត៌មាននៅគ្រប់ករណីទាំងអស់នៃមន្ទីរពេទ្យ ប្រទេសបារាំង។ នៅក្នុង ១១.០.៩៣៤៣ករណី ដែលត្រូវបានធ្វើរោគវិនិច្ឆ័យ នៅចន្លោះឆ្នាំ២០០៨ ដល់ ឆ្នាំ២០១៣ ច្រើនជាង ៥៧០០០ ករណី ជាជំងឺខ្សោយខួរក្បាលមុនវ័យ ដែលមានន័យថា វាកើតមានឡើង មុនអាយុ ៦៥ឆ្នាំ។ នៅក្នុងចំណោមករណីទាំងនេះ បន្ទាប់ពីការដកចេញនូវករណីនៃជំងឺខ្សោយខួរក្បាលដែលបណ្តាលមកពីជំងឺច្បាស់លាស់។ ៥៧% គឺបណ្តាលមកពីការខូចខាតខួរក្បាលដែលពាក់ព័ន្ធទៅនឹងគ្រឿងស្រវឹង ក្នុងនោះ ៣៩% ពិសា ធម្មតា និង ១៨% ពិសាគ្រឿងស្រវឹងលើសចំណុះ។ បន្ទាប់ពីបានរាប់នូវកត្តាដទៃៗទៀតនៃការប្រឈមមុខនឹងជំងឺខ្សោយខួរក្បាល គេឃើញថា ហានិភ័យបានកើនឡើង គុណនឹង ៣.៣៤ សម្រាប់ស្ត្រីនិង៣.៣៦សម្រាប់បុរស។

អាកុលបង្កើនល្បឿននៃការមកដល់នៃជំងឺខ្សោយខួរក្បាល។ អ្នកនិពន្ធនៃការសិក្សាសន្និដ្ឋានថា ការពិសារលើសលុបនៃគ្រឿងស្រវឹងគួរតែត្រូវបានចាត់ទុកជាកត្តាមួយនៅក្នុងចំណោមកត្តាសំខាន់នៃការប្រថុយប្រថាននឹងជំងឺនេះ។ "គ្រឿងស្រវឹងគួរតែអាចបង្កើនល្បឿននៃការមកដល់នៃជំងឺខួរក្បាល និងបង្កើនល្បឿនដល់ការខូចខាតជារចនាសម្ព័ន្ធ និងដំណើរការនៅក្នុងខួរក្បាល"។ នេះគឺជាការពន្យល់នៅក្នុងសេចក្តីប្រកាសព័ត៌មានរបស់វិទ្យាស្ថានជាតិនៃសុខភាព និងការសិក្សាវេជ្ជសាស្ត្របារាំង។

វិបត្តិដែលចងភ្ជាប់ទៅនឹងការពិសាគ្រឿងស្រវឹង គឺប្រហែលជាពាក់ព័ន្ធទៅនឹងការបរិភោគចំណីអាហារមិនល្អ និងរបៀបរបបរស់នៅ ការដក់បារី សញ្ញានៃជំងឺសរសៃឈាមបេះដូង ការត្រួតពិនិត្យដ៏ទន់ខ្សោយបំផុតនៃការព្យាបាលវេជ្ជសាស្ត្រជំងឺធ្លាក់ទឹកចិត្ត ព្រមទាំងភាពឯកោពីសង្គម។

គ្រឿងស្រវឹងគឺជាការប្រឈមមុខដែលមិនអាចបកក្រោយវិញបាន។ អ្នកជំនាញឯករាជ្យ លោកវេជ្ជបណ្ឌិន ដាវីដ លើវីលីន បានអធិប្បាយថា ៖ "ការសិក្សាផ្តល់នូវទិន្នន័យថ្មី ដែលផ្តល់យោបល់ថា វិបត្តិដែលទាក់ទងនឹងគ្រឿងស្រវឹង គឺទាក់ទងយ៉ាងខ្លាំងទៅនឹងការប្រឈមមុខនឹងជំងឺខ្សោយខួរក្បាល"។ លោកវេជ្ជបណ្ឌិល ដាវីដ លើវីលីន ក៏បានលើកឡើងចំនុចខុសគ្នាបន្តិចបន្តួច។ លោកវេជ្ជបណ្ឌិត ដាវីដ លើវីលីន និយាយថា ៖ "ប៉ុន្តែការកាត់បន្ថយការបរិភោគគ្រឿងស្រវឹងឲ្យបានច្រើន ក៏មិនចាំបាច់ក្នុងការកាត់បន្ថយជំងឺខ្សោយខួរក្បាល ឬពន្យាពេលវានោះដែរ"។ អ្នកនិពន្ធនៃការសិក្សាក៏លើកទិន្នន័យថ្មីៗ ជាភស្តុតាងដោយអធិប្បាយថា ៖ "លទ្ធផលនៃការសិក្សាបង្ហាញថាហានិភ័យនៃជំងឺខ្សោយខួរក្បាលក៏អាចកើតមានឡើងបន្ទាប់ពីការតមអាហារផងដែរ។ ចំណែកការពិសាគ្រឿងស្រវឹងបង្កការរបួសដោយផ្ទាល់ដល់ខួរក្បាលជាអចិន្ត្រៃយ៍"។ លោកវេជ្ជបណ្ឌិត ដាវីដ លើវីលីន បានបញ្ជាក់ដែរថា ៖ "ការធ្វើរោគវិនិច្ឆ័យ ការធ្វើអន្តរាគមន៍ភ្លាមៗ ក្នុងករណីនៃការបរិភោគលើសលុបនៃគ្រឿងស្រវឹង និងការព្យាបាលវិបត្តិដែលទាក់ទងទៅនឹងការពិសាលើសលុបនៃជាតិអាកុលគួរតែត្រូវបានរៀបចំឡើងដើម្បីកាត់បន្ថយការព្រួយបារម្ភនៃជំងឺខ្សោយខួរក្បាល"។

ចំណែកលោកការ៉ូ ដុយហ្គួល សហនិពន្ធនៃការសិក្សា បញ្ជាក់ឲ្យច្បាស់ថា ៖ "វិធានការការពារបន្ថែមគួរតែត្រូវបង្កើនឡើង ដើម្បីកាត់បន្ថយការប្រឈមមុខនឹងជំងឺខ្សោយខួរក្បាល ដែលធ្វើឲ្យខូចខាតហិរញ្ញវត្ថុ និងការប៉ះពាល់ដល់សង្គមសេដ្ឋកិច្ច"៕

*ដោយ ផាត សំភី*

# រូបភាពព្រះសហគមន៍ប្រចាំខែ



វេទិកា អន្តរសាសនាថ្នាក់ជាតិនៅកម្ពុជាលើកទី២ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស



ពិធីបុណ្យលើកតម្កើងព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ នៅព្រះវិហារសន្ត ហ្វ្រង់ស្វ័រសាវីយេ វត្តចំប៉ា



អបអរសាទរបុណ្យលើកតម្កើងព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ នៅព្រះសហគមន៍កាតូលិកបាត់ដំបងក្រុង



កម្មវិធីបិទឆ្នាំសិក្សា២០១៧ របស់សាលាមត្តេយ្យសិក្សា នៅក្នុងព្រះសហគមន៍សន្តីម៉ារីតាអំ ភូមិភាគបាត់ដំបង



សិក្ខាសាលាសម្រាប់គ្រូអប់រំជំនឿនៃព្រះសហគមន៍កាតូលិកនៅតំបន់កំពង់ធំ


Radio Veritas Asia

Khmer Service

RADIO VERITAS ASIA-KHMER SERVICE

## វិទ្យុវេរីតាស់អាស៊ីខេមរភាសា

### សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**វិទ្យុវេរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយ៍វិទ្យុ FM នៅភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ យប់ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងសៀមរាប | : FM 100.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងកំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ យប់ |
| ក្រុងកំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |

- លោកអ្នកក៏អាចស្ដាប់កម្មវិធីផ្សាយរបស់វិទ្យុវេរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ www.rvakhmer.com, www.catholiccambodia.org

- លោកអ្នក ក៏អាច Follow face book ផ្លូវការរបស់យើង https://www.facebook.com/RVAKHMER/

**✣ តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្ដាប់កម្មវិធីវិទ្យុវេរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ **Smart Phone** ដែលប្រើប្រព័ន្ធ **Android** ឬប្រព័ន្ធ **IOS** ដោយគ្រាន់តែចូលទៅកាន់ **Play Store** ឬ **App Store** វាយពាក្យ **Radio Varitas Asia** រួច **Download** កម្មវិធីនោះដោយស្វែងរកប៊ូតុង **(Khmer Live Audio)** ។

Radio Varitas Asia

Khmer Live audio

ឬ តាមរយៈវេបសាយ៖ http://rvakhmer.com